សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# ឥទ្ធិពលនៃបដិដុល្លារូបនីយកម្ម មកលើសេដ្ឋកិច្ចកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០២៤ ដល់ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០២៤

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ស៊ូ សៀនលិញ**
**មាន អូសាលីតា**

ណែនាំដោយ
សាស្ត្រាចារ្យរងបណ្ឌិត **ស្រ៊ុន សុភ័ក្ត្រ**

បរិញ្ញាបត្រ **សេដ្ឋកិច្ចអភិវឌ្ឍន៍**
ជំនាន់ទី ០៨

ឆ្នាំចូលសិក្សា ២០២០
ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ ស៊ូ សៀនលិញ និង មាន អូសាលីតា ជានិស្សិតបរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍ ឆ្នាំទី៤ ជំនាន់ទី៨ ក្រុមD4A1 ឆ្នាំសិក្សា ២០២៣-២០២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ នៅក្នុងការសរសេរសារណាបញ្ចប់ឆ្នាំសិក្សានេះយើងទាំងពីរបានជ្រើសរើសប្រធានបទ "**ឥទ្ធិពលនៃបដិវត្តន៍ឌីជីថលរូបនីយកម្មមកលើសេដ្ឋកិច្ចប្រទេសកម្ពុជា**" មកធ្វើការសិក្សាស្រាវជ្រាវ។ យើងខ្ញុំមានសេចក្តីរីករាយ និងកិត្តិយសជាខ្លាំងដែលទទួលបានឱកាសក្នុងការសរសេរសារណាបញ្ចប់ការសិក្សាមួយនេះ។

## សូមគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

លោកអ្នកមានគុណទាំងពីរដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា និងផ្តល់នូវដំបូន្មានល្អៗទូន្មានប្រៀនប្រដៅកូនៗ។ ជាពិសេស លោកទាំងពីរបានជួយទំនុកបម្រុងគាំទ្រ និងផ្គត់ផ្គង់កូនទាំងការរស់នៅ និងការសិក្សារបស់កូនចាប់តាំងពីថ្នាក់បឋមសិក្សារហូតដល់ចប់ថ្នាក់បរិញ្ញាបត្រ។ គុណដ៏ធំធេងនេះកូននឹងខិតខំរៀនសូត្រ ហើយប្រើប្រាស់នូវចំណេះវិជ្ជាទាំងនេះជាប្រយោជន៍សម្រាប់គ្រួសារ និងសង្គមជាតិនាអនាគត។

លោកសាស្ត្រាចារ្យរង **បណ្ឌិត ស្រ៊ុន សុភ័ក្ត្រ** ដែលជាសាស្ត្រាចារ្យណែនាំនៅក្នុងកិច្ចការស្រាវជ្រាវនេះ ចំពោះការផ្តល់ឱវាទ និងចំណាយពេលវេលាដ៏មានតម្លៃមាញឹកក្នុងការណែនាំចង្អុលបង្ហាញ និងផ្តល់ដំបូន្មានល្អៗក្នុងការសរសេរសារណានេះឱ្យដំណើរការប្រកបដោយភាពរលូន និងបានបញ្ចប់ប្រកបដោយជោគជ័យ។ បន្ថែមពីនេះទៀតខ្ញុំក៏សូមអំណរគុណដល់ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង និងសាស្ត្រាចារ្យគ្រប់មុខវិជ្ជា នៃសាកលវិទ្យាភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ដែលបានផ្តល់ជាទីកន្លែងសិក្សាប្រកបដោយការអប់រំល្អ ហើយក៏អរគុណដល់រាមច្បងនិងអ្នកសិក្សាស្រាវជ្រាវទាំងអស់ដែលបានបន្សល់ទុកនូវឯកសារស្រាវជ្រាវ និងអត្ថបទពាក់ព័ន្ធជាច្រើនដែលបានផ្តល់ជាទុនក្នុងការបំផុសគំនិត និងជួយជាមតិយោបល់ល្អៗសម្រាប់យើងខ្ញុំនៅក្នុងការសិក្សាស្រាវជ្រាវនេះ។

ជាចុងក្រោយ យើងខ្ញុំសូមប្រសិទ្ធិពរជ័យទាំង ៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ជូនចំពោះមិត្តអ្នកអាន អ្នកស្រាវជ្រាវ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងមិត្តនិស្សិតទាំងអស់ឱ្យជួបប្រទះតែសំណាងល្អ និងជោគជ័យគ្រប់ភារកិច្ច កុំបីខានឡើយ។

# អារម្ភកថា

នៅក្នុងរយៈពេល៤ឆ្នាំមកនេះ ខ្ញុំពិតជាទទួលបាននូវចំណេះដឹងយ៉ាងច្រើនពីការសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដោយសាស្ត្រាចារ្យដែលបានបង្ហាត់បង្រៀននូវផ្នែកសេដ្ឋកិច្ច និងគោលនយោបាយរូបិយវត្ថុជាច្រើនផងដែរ។ នៅក្នុងនោះអ្វីដែលធ្វើឱ្យយើងខ្ញុំមានការចាប់អារម្មណ៍ជាងគេគឺជាការលំហូរសាច់ប្រាក់ដុល្លារមកប្រទេសកម្ពុជា និងគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិ ដែលជាចំណុចសំខាន់ក្នុងការជួយសេដ្ឋកិច្ចជាតិឱ្យមានភាពរីកចម្រើន។

ដោយទ្បែកប្រាក់ដុល្លារអាមេរិកបានហូរចូលមកប្រទេសកម្ពុជា ជាបន្តបន្ទាប់ក្រោមរូបភាពជាប្រាក់ និងការ វិនិយោគហើយប្រជាពលរដ្ឋក៏បានចាប់ផ្តើមងាកទៅរកការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកក្នុងជីវភាពប្រចាំថ្ងៃ។ ហេតុនេះហើយទើបធ្វើឱ្យយើងខ្ញុំសម្រេចចិត្តធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទ “**ឥទ្ធិពលនៃបដិដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ចប្រទេសកម្ពុជា**” ដោយពិនិត្យមើលទិដ្ឋភាពជាក់ស្តែងដែលកម្ពុជាទទួលបានអំណោយផលពី ស្ថានភាពដុល្លារូបនីយកម្មសេដ្ឋកិច្ចកម្ពុជាប្រឈមនឹងហានិភ័យមួយចំនួនផងដែរដូចជា ហានិភ័យអត្រាប្តូរប្រាក់ ឥទ្ធិពលនៃវិបត្តិសេដ្ឋកិច្ចដែលអាចកើតមានឡើងនៅសហរដ្ឋអាមេរិកជាដើម។ ដូច្នេះដើម្បីត្រៀមខ្លួនសម្រាប់ទប់ទល់នឹងហានិភ័យទាំងនេះ យើងគួរមានការយល់ដឹងឱ្យបានស៊ីជម្រៅទៅលើបញ្ហានេះ និងជាជំនួយដល់ការសម្រេចចិត្តក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុឱ្យមានការអភិវឌ្ឍសង្គមជាតិនាពេលអនាគត។

ជាចុងក្រោយ យើងខ្ញុំសូមអរគុណអ្នកទាំងអស់គ្នាដែលបានចំណាយពេលវេលាដ៏មានតម្លៃមកអានអត្ថបទនេះ។ យើងខ្ញុំក៏សូមអភ័យទោស ចំពោះរាល់កំហុសខុសឆ្គងទាំងឡាយណាដែលកើតឡើងដោយអចេតនានៅក្នុងអត្ថបទស្រាវជ្រាវនេះ ហើយយើងខ្ញុំពេញចិត្តនឹងទទួលការរិះគន់ និងគំនិតថ្មីៗពីសំណាក់អ្នកអានគ្រប់រូប ដើម្បីឱ្យស្នាដៃនេះកាន់តែមានភាពប្រសើរឡើង។

# មាតិកា

ទំព័រ


បញ្ជីអក្សរកាត់ ........ v

បញ្ជីតារាង ........ vi

បញ្ជីក្រាហ្វិក ........ vii

**សេចក្តីផ្តើម** ........ ១

១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២

៣. គោលបំណងនៃការស្រាវជ្រាវ ........ ២

៤. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ........ ២

៥. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ៣

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤

**ជំពូកទី១**

**ការរំលឹកទ្រឹស្តី**

១.១. និយមន័យរូបិយវត្ថុ ........ ៥

១.២. មុខងារនៃរូបិយវត្ថុ ........ ៥

១.២.១. មធ្យោបាយដោះដូរ (Medium of Exchange) ........ ៥

១.២.២. ឯកតាគណនី (Unit of Account) ........ ៦

១.២.៣. មុខងាររក្សាតម្លៃ (Store of Value) ........ ៦

១.៣. ប្រភេទនៃរូបិយវត្ថុ ........ ៦

១.៤. អំពីប្រាក់ដុល្លារ ........ ៧

១.៥. និយមន័យដុល្លារូបនីយកម្ម ........ ៨

១.៦. ប្រភេទដុល្លារូបនីយកម្ម ........ ៨
១.៦.១. ដុល្លារូបនីយកម្មផ្លូវការ ( Official Dollarization ) ........ ៨
១.៦.២. ដុល្លារូបនីយកម្មពាក់កណ្តាលផ្លូវការ ( Semi-official Dollarization ) ........ ៨
១.៦.៣. ដុល្លារូបនីយកម្មមិនផ្លូវការ ( Unofficial Dollarization ) ........ ៨

## ជំពូកទី២

## ឥទ្ធិពលនៃដុល្លារូបនីយកម្មមកលើប្រទេសកម្ពុជា

២.១. ប្រវត្តិនៃការហូរចូលនៃប្រាក់ដុល្លារ ........ ១០
២.១.១. ដំណាក់កាលទី១៖ ការស្តារសេដ្ឋកិច្ចឡើងវិញនៅក្នុងឆ្នាំ១៩៨០ ........ ១០
២.១.២. ដំណាក់កាលទី២៖ ក្រោយការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ........ ១១
២.១.៣. ដំណាក់កាលទី៣៖ ចាប់តាំងពីឆ្នាំ២០០០ ........ ១៣
២.២. ការវិវត្តន៍នៃប្រាក់ដុល្លារមកលើស្ថានភាពប្រទេសកម្ពុជា ........ ១៤
២.៣. ប្រព័ន្ធម៉ាក្រូសេដ្ឋកិច្ច និងដុល្លារូបនីយកម្ម ........ ១៤
២.៣.១ កំណើនសេដ្ឋកិច្ច ........ ១៤
២.៣.២. ការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច ........ ១៦
២.៤. ការវិនិយោគផ្ទាល់ពីបរទេស និងជំនួយពីបរទេស ........ ១៨
២.៥. គុណសម្បត្តិ និងគុណវិបត្តិរបស់ដុល្លារូបនីយកម្ម ........ ២១
២.៥.១. គុណសម្បត្តិរបស់ដុល្លារូបនីយកម្ម ........ ២១
២.៥.២. គុណវិបត្តិរបស់ដុល្លារូបនីយកម្ម ........ ២២

## ជំពូកទី៣

## ស្ថានភាពគោលនយោបាយរូបិយប័ណ្ណនៅប្រទេសកម្ពុជា

៣.១. គោលនយោបាយរូបិយវត្ថុ ........ ២៣
៣.១.១. គោលដៅនៃគោលនយោបាយរូបិយវត្ថុ ........ ២៣

៣.១.២. ប្រភេទនៃគោលនយោបាយរូបិយវត្ថុ ........ ២៤
៣.២. គោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិកម្ពុជា ........ ២៤
៣.៣. សារៈប្រយោជន៍នៃការប្រើប្រាស់ប្រាក់រៀល ........ ២៥
៣.៣.១. លើកតម្កើងអត្តសញ្ញាណជាតិ ........ ២៥
៣.៣.២. រក្សាស្ថិរភាពថ្លៃ ........ ២៦
៣.៣.៣. កាត់បន្ថយចំណាយប្រតិបត្តិការ ........ ២៦
៣.៣.៤. ជំរុញពាណិជ្ជកម្ម ........ ២៦
៣.៣.៥. ជំរុញការវិនិយោគ ........ ២៦
៣.៣.៦. លើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធ និងសុខុមាលភាពសង្គម ........ ២៧
៣.៣.៧. ទទួលបានចំណូលពីការបោះពុម្ពក្រដាសប្រាក់ ........ ២៧
៣.៣.៨. បង្ការការក្លែងក្រដាសប្រាក់ ........ ២៧
៣.៤. ការលើកកម្ពស់ប្រាក់រៀលក្នុងគោលនយោបាយរបស់ធនាគារជាតិនៃកម្ពុជា ........ ២៧
៣.៤.១. ការលើកកម្ពស់ប្រាក់រៀលក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ........ ២៧
៣.៤.២. ការលើកកម្ពស់ប្រាក់រៀលក្នុងទសវត្សរ៍ឆ្នាំ ២០០០ ........ ២៨
៣.៤.៣. ការលើកកម្ពស់ប្រាក់រៀលចាប់តាំងពីឆ្នាំ ២០១០ ........ ២៩

## ជំពូកទី៤

## ការវិភាគទិន្នន័យ និងការបកស្រាយទិន្នន័យ

៤.១. ការប្រើប្រាស់រូបិយប័ណ្ណបរទេសក្នុងប្រតិបត្តិការប្រចាំថ្ងៃ ........ ៣១
៤.២. ចំណូលចិត្តសម្រាប់រូបិយប័ណ្ណតាមទំហំប្រតិបត្តិការ ........ ៣៤
៤.៣. ការកម្ចីប្រាក់របស់គ្រួសារ ........ ៣៦
៤.៤. ការពិភាក្សា ........ ៣៨

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

សេចក្តីសន្និដ្ឋាន ........ ៤១

អនុសាសន៍.....................................................................................................................៤២

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

ASEAN : សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍

ATM : ម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ

CDC : ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

DAC : គណៈកម្មាធិការជំនួយអភិវឌ្ឍន៍

FDI : វិនិយោគផ្ទាល់ពីបរទេស

GDP : ផលិតផលក្នុងស្រុកសរុប

GNI : ចំណូលជាតិសរុប

IMF : មូលនិធិរូបិយវត្ថុអន្តរជាតិ

JICA : ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន

KHR : ប្រាក់រៀលកម្ពុជា

LPCO : ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា

MFIs : គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជា

NBC : ធនាគារជាតិនៃកម្ពុជា

NDCs : មូលបត្រអាចជួញដូរបាន

ODA : ជំនួយអភិវឌ្ឍន៍ផ្លូវការ

OECD : អង្គការសម្រាប់ការអភិវឌ្ឍ និងសហប្រតិបត្តិការសេដ្ឋកិច្ច

QIP : គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

QR : ការស្កេនឆ្លងកូដ

THB : ប្រាក់បាតថៃ

UNTAC : អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិ

VND : ប្រាក់ដុងវៀតណាម

WTO : អង្គការពាណិជ្ជកម្មពិភពលោក

# បញ្ជីតារាង


តារាងទី១ ៖ អត្រាកំណើនផលិតផលក្នុងស្រុកសរុប គិតជាមធ្យមក្នុងមនុស្សម្នាក់

តារាងទី២ ៖ សមាមាត្រជាមធ្យមនៃការចំណាយជារូបិយប័ណ្ណបរទេសទៅនឹងការចំណាយសរុប

តារាងទី៣ ៖ ការជ្រើសរើសរូបិយប័ណ្ណផ្សេងៗសម្រាប់ធ្វើការកម្ចីប្រាក់

តារាងទី៤ ៖ មូលហេតុនៃការជ្រើសរើសកម្ចីនៃរូបិយប័ណ្ណផ្សេងៗ

# បញ្ជីក្រាហ្វិក

ក្រាហ្វិកទី១ ៖ បម្រែបម្រួលផលិតផលក្នុងស្រុកនៅក្នុងវិស័យនីមួយៗ

ក្រាហ្វិកទី២ ៖ បំណែកការងារតាមវិស័យនីមួយៗ

ក្រាហ្វិកទី៣ ៖ ចំណែកនៃជំនួយអភិវឌ្ឍន៍ផ្លូវការ និងការវិនិយោគផ្ទាល់ពីបរទេស

ក្រាហ្វិកទី៤ ៖ មធ្យមភាពនៃការចំណាយជារូបិយប័ណ្ណបរទេស និងរូបិយវត្ថុជាតិរបស់គ្រួសារតាមតំបន់ និងតាមកម្រិតនៃប្រាក់ចំណូលទៅនឹងការចំណាយសរុប

ក្រាហ្វិកទី៥ ៖ ភាពខុសគ្នានៃការជ្រើសរើសប្រាក់ចំណូលជារូបិយប័ណ្ណបរទេសរបស់គ្រួសារតាមតំបន់ និងតាមកម្រិតនៃប្រាក់ចំណូល

ក្រាហ្វិកទី៦ ៖ ចំណង់ចំណូលចិត្តរូបិយប័ណ្ណតាមទំហំនៃប្រតិបត្តិការការលក់

ក្រាហ្វិកទី៧ ៖ ចំណង់ចំណូលចិត្តរូបិយប័ណ្ណសម្រាប់ការលក់ទំនិញ ឬសម្ភារៈផ្សេងៗ

ក្រាហ្វិកទី៨ ៖ បំណុលរបស់គ្រួសារតាមកម្រិតនៃប្រាក់ចំណូល និងតាមតំបន់

# សេចក្ដីផ្ដើម

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

រូបិយវត្ថុ គឺជាផលិតផលដ៏សំខាន់មួយនៅក្នុងទីផ្សារសេដ្ឋកិច្ចដើម្បីបង្កើតលក្ខណៈងាយស្រួលដល់ដំណើរការដោះដូរទំនិញ ឬសេវាកម្ម។ វាជាវត្ថុមួយដែលត្រូវបានគេប្រើប្រាស់ជាមធ្យោបាយដើម្បីដោះដូរទំនិញ ឬសេវាកម្ម និងទូទាត់បំណុលផ្សេងៗទៀត។ រហូតមកដល់បច្ចុប្បន្ន រូបិយវត្ថុបានផ្លាស់ប្ដូរពីកាក់មកជាក្រដាសប្រាក់ជាច្រើនរូបរាង ហើយអ្នកជំនាញបានផ្លាស់ប្ដូររូបរាងរូបិយវត្ថុពីមួយឆ្នាំទៅមួយឆ្នាំឥតឈប់ឈរ ដើម្បីបង្កភាពងាយស្រួលដល់អ្នកប្រើប្រាស់។ រូបិយវត្ថុមិនដែលបាត់បង់នូវមុខងារដ៏អស្ចារ្យរបស់ខ្លួនឡើយ ព្រោះវាបានដើរតួយ៉ាងសំខាន់លើការរៀបចំសណ្ដាប់ធ្នាប់នៃកិច្ចការជំនួញប្រកបដោយសន្តិភាព និងការរៀបចំឱ្យមានឯកទេសកម្មនិងការរីកចម្រើន។

ជាទូទៅនៅពេលដែលប្រទេសមួយជួបនូវវិបត្តិសេដ្ឋកិច្ច អស្ថេរភាពសង្គម អតិផរណា ឬមានប្រព័ន្ធហិរញ្ញវត្ថុរបស់ខ្លួនបាត់បង់ទំនុកចិត្តពីប្រជាជន ប្រទេសនោះអាចនឹងងាកមកប្រើប្រាស់រូបិយប័ណ្ណបរទេសដែលមានស្ថិរភាពមកជួយស្ដារទំនុកចិត្តលើប្រព័ន្ធហិរញ្ញវត្ថុរបស់ពួកគេវិញ និងបង្កើតឱកាសកាន់តែច្រើនសម្រាប់កំណើនសេដ្ឋកិច្ចខ្លួន។ ប្រទេសកម្ពុជា មានរូបិយវត្ថុផ្លូវការជាប្រាក់រៀល ប៉ុន្តែប្រទេសកម្ពុជាក៏មានការចរចារប្រាក់ដុល្លារយ៉ាងទូលំទូលាយក្នុងប្រទេសផងដែរ។ កម្ពុជាបានចាប់ផ្ដើមចរចារប្រាក់ដុល្លារអាមេរិកនៅឆ្នាំ ១៩៩០ ដោយសារក្នុងប្រទេសមានអស្ថេរភាពផ្នែកសេដ្ឋកិច្ច និងនយោបាយ កង្វះទំនុកចិត្តលើប្រាក់រៀល អតិផរណាខ្ពស់ និងអស្ថេរភាព គួបផ្សំនឹងការហូរចូលនៃប្រាក់ដុល្លារបានធ្វើឱ្យមានការទទួលស្គាល់ នៅប៉ុន្មានទសវត្សរ៍ចុងក្រោយមកនេះ ប្រទេសកម្ពុជាមានការរីកចម្រើនផ្នែកម៉ាក្រូសេដ្ឋកិច្ច និងស្ថេរភាពនយោបាយគួរឱ្យកត់សម្គាល់។ សេដ្ឋកិច្ចកម្ពុជាមានការកើនឡើងជាលំដាប់នៅពាក់កណ្ដាលទសវត្សរ៍ឆ្នាំ ១៩៩០ នឹងរំពឹកទុកក្លាយជាប្រទេសមួយមានចំណូលមធ្យមកម្រិតខ្ពស់នាពេលអនាគត។ កត្តាដែលធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាមានការរីកចម្រើនដោយសារការវិនិយោគពីបរទេស (FDI) មានការកើនឡើង និងការកើនឡើងនៃការនាំចេញផ្នែកឧស្សាហកម្មវាយនភ័ណ្ឌ និងកាត់ដេរ។ ទាំងនេះក៏ជាកត្តាដែលធ្វើឱ្យប្រទេសកម្ពុជាមានទំនោរខ្ពស់ទៅរកលុយដុល្លារដោយសារការជួញដូរ ឬការនាំចេញនាំចូល គិតជាប្រាក់ដុល្លារទាំងអស់ ទើបធ្វើឱ្យកម្លាំងជំរុញនៃកំណើនសេដ្ឋកិច្ចរបស់កម្ពុជា គឺពឹងផ្អែកខ្លាំងពេកនៅលើប្រាក់ដុល្លារនៅក្នុងគ្រប់ទិដ្ឋភាពនៃវិធីទូទាត់ប្រាក់ និងការបង្កើតទ្រព្យសកម្ម ហើយដូច្នេះ វាពិបាកឆ្លើយតបតាមរយៈគោលនយោបាយរូបិយវត្ថុរបស់ខ្លួន។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជា ជាប្រទេសមួយដែលប្រើប្រាស់ប្រាក់ដុល្លារអាមេរិកមានទំហំច្រើនជាងប្រាក់រៀលជាតិគួរឱ្យកត់សម្គាល់។ ការប្រើប្រាស់រូបិយប័ណ្ណដុល្លារនៅក្នុងកម្ពុជាបានចាប់ផ្តើមក្នុងឆ្នាំ ១៩៩០ បណ្តាលមកពីភាពអស្ថិរភាពនយោបាយ និងបញ្ហាសេដ្ឋកិច្ច។ រូបិយប័ណ្ណដុល្លារបានក្លាយជាជម្រើសមួយដែលប្រជាជនកម្ពុជាសម្រាប់ការទូទាត់ ការសន្សំ និងការវិនិយោគ ដោយសារតែមានស្ថេរភាព។

ដូច្នេះហើយ បានជាពួកយើងធ្វើការសិក្សាស្រាវជ្រាវចង់ដឹងឱ្យកាន់តែច្បាស់លាស់ទើបមានចំណោទបញ្ហាទាំងនេះលើកឡើងដូចតទៅ៖

1. តើស្ថានភាពដុល្លារូបនីយកម្មមានឥទ្ធិពលយ៉ាងដូចម្តេចមកលើសេដ្ឋកិច្ចប្រទេសកម្ពុជា ?
2. តើកត្តាអ្វីខ្លះដែលបណ្តាលឱ្យកើតមានឡើងនៃដុល្លារូបនីយកម្មនៅក្នុងសេដ្ឋកិច្ចកម្ពុជា ?
3. តើដុល្លាររូបនីយកម្មនៅកម្ពុជាមានគុណសម្បត្តិ និងគុណវិបត្តិអ្វីខ្លះ ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាលើប្រធានបទនេះ ធ្វើឡើងក្នុងគោលបំណងសំខាន់ៗដូចខាងក្រោម៖

- សិក្សាពីប្រវត្តិ និងការកកើតនៃដុល្លារូបនីយកម្មនៅកម្ពុជា
- ស្វែងយល់ពីឥទ្ធិពលរបស់ប្រាក់ដុល្លារអាមេរិកមកលើសេដ្ឋកិច្ចកម្ពុជា
- សិក្សាពីសក្តានុពលគ្រប់គ្រងប្រាក់ដុល្លារ និងពង្រឹងស្ថិរភាពសេដ្ឋកិច្ចនៅប្រទេសកម្ពុជា
- សិក្សាពីកត្តាដែលបណ្តាលឲ្យកើតមានដុល្លារូបនីយកម្មនៅក្នុងសេដ្ឋកិច្ចកម្ពុជា
- សិក្សាពីស្ថានភាពរបស់ដុល្លារូបនីយកម្មនៅប្រទេសកម្ពុជា
- សិក្សាពីគុណសម្បត្តិ និងគុណវិបត្តិនៃការប្រើប្រាស់ប្រាក់ដុល្លារជាមួយអ្នកដែលពាក់ព័ន្ធនានារួមមានរដ្ឋាភិបាល ការធ្វើពាណិជ្ជកម្ម អ្នកវិនិយោគ និងការទូទាត់ប្រចាំថ្ងៃ។

## ៤. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

សារៈសំខាន់នៃអត្ថបទការស្រាវជ្រាវមួយនេះ គឺចង់បង្ហាញដល់អ្នកអាន និងនិស្សិតជំនាន់ក្រោយឱ្យយល់ដឹងអំពី៖

- ផ្តល់ចំណេះដឹងដល់អ្នកអានឱ្យយល់កាន់តែយល់ច្បាស់ពីការគ្រប់គ្រងគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិកម្ពុជា
- សារៈសំខាន់នៃការហូរចូលប្រាក់ដុល្លារមកលើកំណើនសេដ្ឋកិច្ចនៅប្រទេសកម្ពុជា

- យល់ពីគោលនយោបាយ ឬយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលមកលើប្រាក់ដុល្លារ
- ចូលរួមចំណែកដែលជួយជំរុញនូវវិធានការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលក្នុងស្រុកឱ្យមានភាពប្រសើរឡើង
- ជាឯកសារសម្រាប់និស្សិតជំនាន់ក្រោយ ឬបុគ្គលដែលមានបំណងចង់សិក្សាទៅលើប្រាក់ដុល្លារ។

## ៥. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ គឺបានផ្តោតសំខាន់ទៅលើដំណើរការបដិដុល្លារូបនីយកម្មក្នុងសេដ្ឋកិច្ចកម្ពុជា ដោយផ្តោតទៅលើប្រពន្ធ័សេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា អនុវត្តន៍គោលនយោបាយនានារបស់ធនាគារជាតិ និងដើម្បីលើកកម្ពស់ការប្រើប្រាស់រូបិយប័ណ្ណរៀល ព្រមទាំងអ្នកពាក់ព័ន្ធនានា ក្នុងការគ្រប់គ្រងវិធានការផ្សេងៗរបស់រូបិយវត្ថុនេះសិក្សាចន្លោះពីឆ្នាំ (១៩៩៥-២០២០) ដែលចេញដោយធនាគារជាតិនៃកម្ពុជាស្ថិតក្នុងផ្នែកស្រាវជ្រាវសេដ្ឋកិច្ច ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវនេះ បានជ្រើសរើសយកវិធីសាស្ត្រនៃការស្រាវជ្រាវដោយផ្តោតសំខាន់លើទិន្នន័យបន្ទាប់បន្សំ (Secondary Data) ។ ទិន្នន័យដែលមាន ឯកសារច្បាស់លាស់ ដូចជារបាយការណ៍ និងការសិក្សាស្រាវជ្រាវផ្សេងៗដែលបោះពុម្ពឯកសារដោយធនាគារជាតិនៃកម្ពុជា សៀវភៅសេដ្ឋកិច្ចផ្សេងៗដែលបោះពុម្ពជាអន្តរជាតិ ជាភាសាអង់គ្លេសដោយសាស្ត្រាចារ្យល្បីល្បាញ ឯកសារពីអ៊ិនធើណេត សៀវភៅសារណា និងរបាយការណ៍បញ្ចប់កម្មសិក្សារបស់និស្សិតជំនាន់មុនៗ និងឯកសារពាក់ព័ន្ធមួយចំនួនជាច្រើនទៀតនៅតាមបណ្ណាល័យនានា។

<u>ប្រភពទិន្នន័យ</u> ៖

- សៀវភៅរបាយការណ៍សេដ្ឋកិច្ចរបស់ធនាគារជាតិនៃកម្ពុជា
- អត្ថបទស្រាវជ្រាវរបស់ស្ថាប័នអន្តរជាតិ ធនាគារអភិវឌ្ឍន៍អាស៊ី មូលនិធិរូបិយវត្ថុអន្តរជាតិ អង្គការពាណិជ្ជកម្មពិភពលោក ធនាគារពិភពលោក
- គោលនយោបាយ ឬយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលមកលើរូបិយប័ណ្ណបរទេស
- អត្ថបទបានមកពីប្រព័ន្ធអ៊ិនធើណេត និងលំនាំសារណារបស់សិស្សច្បងជំនាន់មុន។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងរចនាសម្ព័ន្ធនៃការស្រាវជ្រាវនេះ ត្រូវបានបែងចែកជាបួន ជំពូកធំៗ គឺ

- **សេចក្តីផ្តើម** ៖ ក្នុងផ្នែកនេះបង្ហាញពី លំនាំបញ្ហា ចំណោទបញ្ហា គោលបំណងនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ទំហំនិងដែនកំណត់ វិធីសាស្ត្រនៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ ។
- **ជំពូកទី១ ការរំលឹកទ្រឹស្តី** ៖ នៅក្នុងផ្នែកនេះបានបង្ហាញអំពីនិយមន័យរូបិយវត្ថុ មុខងាររូបិយវត្ថុមធ្យោបាយដោះដូរ ឯកតាគណនី មុខងាររក្សាតម្លៃ ប្រភេទនៃរូបិយវត្ថុ និងអំពីប្រាក់ដុល្លារ និយមន័យដុល្លារូបិយនីយកម្ម និងប្រភេទដុល្លារូបនីយកម្ម ។
- **ជំពូកទី២ ឥទ្ធិពលនៃបដិដុល្លារូបនីយកម្មលើសេដ្ឋកម្មកម្ពុជា** ៖ និយាយអំពីប្រវត្តិនៃការហូរចូលនៃប្រាក់ដុល្លារ ការវិវត្តន៍នៃប្រាក់ដុល្លារមកលើស្ថានភាពប្រទេសកម្ពុជា ប្រព័ន្ធម៉ាក្រូសេដ្ឋកិច្ច និងដុល្លារូបនីយកម្ម កំណើនសេដ្ឋកិច្ច ការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច ការវិនិយោគផ្ទាល់ពីបរទេស និងជំនួយពីបរទេសគុណសម្បត្តិ និងគុណវិបត្តិរបស់ដុល្លារូបិយនីយកម្ម ។
- **ជំពូកទី៣ ទិដ្ឋភាពទូទៅនៃវិស័យរូបិយវត្ថុនៅប្រទេសកម្ពុជា** ៖ ក្នុងជំពូកនេះបង្ហាញពីគោលនយោបាយរូបិយវត្ថុនៅកម្ពុជា វិធានការជួយលើកកម្ពស់ប្រាក់រៀលឱ្យមានស្ថិរភាពល្អប្រសើរតាមគោលគំនិតរបស់ធនាគារជាតិកម្ពុជា។
- **ជំពូកទី៤ ការវិភាគទិន្នន័យ និងការបកស្រាយទិន្នន័យ** ៖ បកស្រាយអំពី ការវិភាគទៅលើការប្រើប្រាស់ប្រាក់ដុល្លារក្នុងគ្រួសារ និងដុល្លារូបនីយកម្មនៅកម្ពុជា។
- **សេចក្តីសន្និដ្ឋាន និងអនុសាសន៍** ៖ សរុបខ្លឹមសាររួមនៃសារណា ធ្វើសេចក្តីសន្និដ្ឋានទៅលើការសិក្សាស្រាវជ្រាវបដិដុល្លារូបនីយកម្មកម្ពុជានេះ និងផ្តល់ជាអនុសាសន៍សំខាន់ៗជំរុញឱ្យមានប្រសទ្ធិភាពក្នុងលើកកម្ពស់ប្រាក់រៀល សម្រាប់ជាការអភិវឌ្ឍនាពេលអនាគត។
- **ឯកសារយោង**
- **ឧបសម្ព័ន្ធ**

# ជំពូកទី១

# ការរំលឹកទ្រឹស្តី

# ជំពូកទី១

# ការរំលឹកទ្រឹស្តី

## ១.១. និយមន័យរូបិយវត្ថុ

រូបិយវត្ថុ គឺជាឧបករណ៍ ឬវត្ថុមួយដែលគេប្រើប្រាស់ធ្វើការជាមធ្យោបាយដោះដូរក្នុងការទូទាត់ទំនិញ សេវាកម្ម និងទូទាត់សងបំណុលផ្សេងៗ[1]។

យោងតាមវចនានុក្រមរបស់សម្តេចសង្ឃ ជួន ណាត រូបិយវត្ថុ គឺមកពីពាក្យ រូបិយៈ ដែលមានន័យថា ប្រាក់ ប្រាក់ឬមាសឬលោហជាតិមានទង់ដែងជាដើមដែលមានរូបសណ្ឋានឬត្រាជាគ្រឿងសម្គាល់ សម្រាប់ចាយរាល់ប្រទេសទោះវត្ថុដទៃក្រៅពីប្រាក់មាសនិងលោហជាតិដែលរដ្ឋបាលក្នុងប្រទេសនីមួយៗបញ្ញត្តិឱ្យប្រើជារបស់សម្រាប់ចាយជាជំនួសប្រាក់មាស ដូចយ៉ាងធនបត្រដែលប្រើក្នុងសម័យសព្វថ្ងៃនេះក៏ហៅ រូបិយៈ បានដែរ[2]។

រូបិយវត្ថុពីដើមមានលក្ខណៈជារបស់ដែលមានតម្លៃ ដូចជា៖ លោហធាតុ សំបកខ្យង សំណរ ស្ពាន់ ប្រាក់ ជាដើម។ ចំណែករូបិយវត្ថុជាក្រដាសប្រាក់វិញ ត្រូវបានគេឃើញមាននៅពាក់កណ្តាលសតវត្សទី ១៧ មកម្ល៉េះ។ ក្រៅពីនេះ មានរូបិយវត្ថុជាលក្ខណៈតួលេខក្នុងគណនីនៅសតវត្សទី២០ ដែលជាយុគសម័យចាប់ផ្តើមក្នុងជីវិតសេដ្ឋកិច្ចនៃប្រទេសនីមួយៗ។

## ១.២. មុខងារនៃរូបិយវត្ថុ[3]

រូបិយវត្ថុមានមុខងារសំខាន់ៗ ៣ដូចខាងក្រោម ៖

### ១.២.១. មធ្យោបាយដោះដូរ ( Medium of Exchange )

គឺការធ្វើពាណិជ្ជកម្មទំនិញ និងសេវា ជាមួយទំនិញនិងសេវាផ្សេងទៀតដោយគ្មានការប្រើលុយ ឬមមានការដោះដូរទូទាត់រវាងទំនិញ ឬសេវាមួយ ជាមួយទំនិញ និងសេវាផ្សេងទៀត ដោយមិនប្រើការដោះដូរជាមួយរូបិយវត្ថុ គឺជាការទទួលស្គាល់ជាទូទៅរវាងអ្នកលក់ និងអ្នកទិញក្នុងការដោះដូរទំនិញ និងសេវាកម្មទៅវិញទៅមក ។

[1] Wikipedia, "រូបិយវត្ថុ", បានកែសម្រួលនៅថ្ងៃទី០៤ វិច្ឆិកា ២០២៣, រូបិយវត្ថុ - វិគីភីឌា ( wikipedia.org )

[2] ដកស្រង់ចេញពីវចនានុក្រមខ្មែររបស់ សម្តេចសង្ឃ ជួន ណាត, បានចូលទាញនៅថ្ងៃទី ១៥ មិថុនា ២០២៤

[3] Facebook (ស្វែងយល់ពាក្យបច្ចេកទេស), "មុខងាររូបិយវត្ថុ", ០៨ កក្កដា ២០១៩, https://www.facebook.com/share/1YhrZAJLL9P6mGcw/?mibextid=WC7FNe

**១.២.២. ឯកតាគណនី** (Unit of Account)

គឺជាការវាស់វែងស្ថានភាពថ្លៃនាពេលដែលអ្នកប្រើប្រាស់ ឬ អតិថិជនបាន គិតគូរអំពីតម្លៃសមស្របនៃទំនិញ និងសេវាកម្មដែលគេចង់បាន។

**១.២.៣. មុខងាររក្សាតម្លៃ** (Store of Value)

សំដៅទៅលើផលិតផល ឬទំនិញទាំងឡាយ ឬវត្ថុតាងនានាដែលអាចយកទៅប្រើប្រាស់ជាថ្នូរក្នុងការដោះដូរទំនិញ និងសេវាកម្មក្រោយពីការកាន់កាប់ទុកមួយរយៈ។ រូបិយវត្ថុមានមុខងារសំខាន់ៗគឺ មធ្យោបាយដោះដូរ ខ្នាតវាស់តម្លៃ និងមុខងាររក្សាតម្លៃ។

## ១.៣. ប្រភេទនៃរូបិយវត្ថុ[4]

រូបិយវត្ថុត្រូវបានគេឱ្យនិយមន័យថា ជាវត្ថុទាំងឡាយណាដែលត្រូវបានគេទទួលស្គាល់ជាទូទៅនៅក្នុងការទូទាត់លើថ្លៃទំនិញ និងសេវាកម្ម។ រូបិយវត្ថុត្រូវបានផ្លាស់ប្តូរពីមាស ប្រាក់ កាក់ ទៅជាក្រដាសប្រាក់ និងទៅជាប្រាក់នៅក្នុងម៉ាស៊ីនអេឡិចត្រូនិច។ ឧទាហរណ៍ដូចជា៖ សាច់ប្រាក់ បានគេដាក់ និងធ្វើប្រតិបត្តិការដកប្រាក់តាមរយៈម៉ាស៊ីនអេឡិចត្រូនិច(ATM)និងវិក័យបត្រត្រូវបានចំណាយ និងធ្វើប្រតិបត្តិការតាមប្រព័ន្ធអិនធឺណេត (Online)។ រូបិយវត្ថុត្រូវបានបែងចែកជា ៤ យ៉ាង៖

- M0: ជារង្វាស់តូចបំផុតនៃការផ្គត់ផ្គង់រូបិយវត្ថុដែលជារួមមានសាច់ប្រាក់កម្កល់នៅក្នុងធនាគារ និង ចំនួនទឹកប្រាក់ដែលធ្វើចរាចរនៅក្នុងសេដ្ឋកិច្ច។ M0 រួមមានសាច់ប្រាក់ ឬ ទ្រព្យសកម្មដែលអាចបម្លែងជារូបិយប័ណ្ណភ្លាមៗ។

- M1 (Currency): ជាប្រភេទនៃកាតផ្គត់ផ្គង់សាច់ប្រាក់ដែលរួមមាន កាក់ ក្រដាសប្រាក់។ M1 ត្រូវបានគេប្រើប្រាស់ដើម្បីកំណត់នូវបរិមាណសាច់ប្រាក់ដែលធ្វើចរាចរ។ M1 រួមមានសាច់ប្រាក់ ឬទ្រព្យសកម្មដែលអាចបម្លែងជារូបិយប័ណ្ណបានភ្លាមៗដែរ។

**M1 = Bank Notes + Coins**

- M2: ជាប្រភេទមួយនៅក្នុងការផ្គត់ផ្គង់រូបិយវត្ថុដែរ ដោយរួមបញ្ចូលទាំង M1 និងរាល់ការដាក់សាច់ប្រាក់ ការសន្សំ និងមូលធននៅក្នុងស្ថាប័នមិនមែនទីផ្សាររូបិយវត្ថុ។ M2 មានលក្ខណៈទូលាយ

[4] ដកស្រង់ចេញពី លោកសាស្ត្រចារ្យ ងួន ហេង, "សៀវភៅរូបិយវត្ថុ និងធនាគារ", ឆ្នាំ២០១៥, ទំព័រ៨និង៩, បានចូលទាញនៅថ្ងៃទី ២០ ឧសភា ២០២៤

ជាង M1 ។ អ្នកសេដ្ឋកិច្ចប្រើប្រាស់ M2 ដើម្បីពិនិត្យមើលទៅលើចំនួនសាច់ប្រាក់ដែលចរាចរនៅក្នុងសេដ្ឋកិច្ច និងដើម្បីបង្ហាញនូវលក្ខខ័ណ្ឌសេដ្ឋកិច្ចរូបិយវត្ថុ។

**M2 = M1 + Deposit**

- M3: ជាប្រភេទមួយរបស់ការផ្គត់ផ្គង់រូបិយវត្ថុ ដែលរួមមាន M2 និងការដាក់ប្រាក់ដែលមានរយៈពេលវែង មូលធនពីស្ថាប័នទីផ្សារូបិយវត្ថុ កិច្ចសន្យាទិញរយៈពេលខ្លី និងទ្រព្យសកម្មដែលអាចបម្លែងជាសាច់ប្រាក់ដែលមានមួយចំនួនធំ។ M3 មានលក្ខណៈទូលាយជាង M2 ជារង្វាស់នៃការផ្គត់ផ្គង់រូបិយវត្ថុដែលមានលក្ខណៈទូលាយបំផុត ហើយត្រូវបានអ្នកសេដ្ឋកិច្ចប្រើប្រាស់ដើម្បីប៉ាន់ស្មានការផ្គត់ផ្គង់ រូបិយវត្ថុនៅក្នុងសេដ្ឋកិច្ចទាំងមូល។

**M3 = M2 + repurchase agreements + money market fund shares + debt securities with a maturity of up to and including 2 years**

## ១.៤. អំពីប្រាក់ដុល្លារ[5]

នៅកម្ពុជា ដុល្លារអាមេរិក ត្រូវបានគេប្រើប្រាស់ជាមធ្យោបាយសម្រាប់កំណត់តម្លៃ សម្រាប់ទូទាត់ និងសម្រាប់សន្សំ ពោលគឺ តួនាទីសំខាន់ៗទាំង៣ នៃរូបិយប័ណ្ណ។ តម្លៃទំនិញភាគច្រើនត្រូវគិតជាដុល្លារ ការទិញដូរភាគច្រើនត្រូវទូទាត់ដោយប្រើលុយដុល្លារ ហើយការដាក់លុយសន្សំនៅធនាគារ ភាគច្រើនត្រូវដាក់ជាដុល្លារ។

យោងតាមមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) នៅកម្ពុជា ដុល្លារត្រូវបានប្រើប្រាស់រហូតទៅដល់ប្រមាណជា ៨0% នៃបរិមាណសាច់ប្រាក់សរុបដែលចរាចរនៅលើទីផ្សារ ហើយខុសពីប្រទេសជិតខាងដូចជា ប្រទេសឡាវ ជាដើមដែលការប្រើលុយដុល្លារមានការថយចុះធៀបនឹងលុយជាតិ និន្នាការនៃការប្រើលុយដុល្លារនៅកម្ពុជាវិញមិនមានការថយចុះទាល់តែសោះ បើទោះបីជាកម្ពុជាមានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ហើយមានអត្រាអតិផរណាមិនខ្ពស់ហួសហេតុក៏ដោយ។

ការអនុញ្ញាតឱ្យចាយលុយដុល្លារយ៉ាងទូលំទូលាយបែបនេះ អាចផ្តល់នូវគុណប្រយោជន៍មួយចំនួនក៏ប៉ុន្តែ ក៏អាចបង្កនូវផលវិបាកអវិជ្ជមានច្រើនផងដែរដល់សេដ្ឋកិច្ចខ្មែរ។

[5] Sem Kimchhay, "ដុល្លារូបនីយកម្ម", ០៥ កុម្ភៈ ២០១៧, ដុល្លារូបនីយកម្ម - វិគីភីឌា (wikipedia.org)

## ១.៥. និយមន័យដុល្លារូបនីយកម្ម[6]

ដុល្លារូបនីយកម្ម គឺសំដៅដល់បាតុភូតដែលប្រជាពលរដ្ឋនៃប្រទេសមួយបានសម្រេចចិត្តជ្រើសរើសប្រើប្រាស់រូបិយប័ណ្ណបរទេស ទោះជាយ៉ាងណាដូចជាប្រាក់ដុល្លារអាមេរិក ឬរូបិយប័ណ្ណផ្សេងទៀត ជំនួសឬទន្ទឹមនឹងការប្រើប្រាស់រូបិយវត្ថុជាតិនៃប្រទេសនោះ។

គួរបញ្ជាក់ថា ដុល្លារូបនីយកម្មមិនមែនសំដៅតែការប្រើប្រាក់ដុល្លារជំនួសរូបិយវត្ថុក្នុងស្រុកប៉ុណ្ណោះនោះទេ តែការប្រើប្រាក់ផ្សេងទៀត ដូចជាប្រាក់បាត ប្រាក់ដុង ឬប្រាក់យ័ន ក៏គេចាត់ទុកថាជាដុល្លារូបនីយកម្មដែរ។

## ១.៦. ប្រភេទដុល្លារូបនីយកម្ម

ដុល្លារូបនីយកម្មត្រូវបានគេបែងចែកជា៣ ធំៗដូចជា៖

### ១.៦.១. ដុល្លារូបនីយកម្មផ្លូវការ (Official Dollarization)

ដុល្លារូបនីយកម្មផ្លូវការ ឬពេញលេញ (Official Dollarization) ៖ គឺជាស្ថានភាពមួយដែលរូបិយប័ណ្ណបរទេសត្រូវបានអនុម័តជាផ្លូវការដើម្បីប្រើប្រាស់ដោយស្របច្បាប់ជំនួសរូបិយវត្ថុក្នុងស្រុក។ ការសម្រេចចិត្តនេះត្រូវបានគេសង្កេតឃើញនៅក្នុងប្រទេសមួយចំនួនដែលធ្លាប់បានជួបវិបត្តិសេដ្ឋកិច្ចធ្ងន់ធ្ងរ និងការបាត់បង់ជំនឿចិត្តទាំងស្រុងលើរូបិយប័ណ្ណជាតិខ្លួន។

### ១.៦.២. ដុល្លារូបនីយកម្មពាក់កណ្ដាលផ្លូវការ (Semi-official Dollarization)

ដុល្លារូបនីយកម្មពាក់កណ្ដាលផ្លូវការ (Semi-official Dollarization) ៖ គឺសំដៅដល់ស្ថានភាពដែលរូបិយប័ណ្ណបរទេស និងរូបិយវត្ថុជាតិត្រូវបានប្រើប្រាស់ដោយសេរីនៅក្នុងទីផ្សារ ដោយសារតែប្រជាពលរដ្ឋភាគច្រើន យល់ថារដ្ឋាភិបាលទទួលយកការប្រើប្រាស់រូបិយប័ណ្ណបរទេស បើទោះបីជាមិនមានការប្រកាសជាផ្លូវការពីការទទួលស្គាល់ក៏ដោយ។

### ១.៦.៣. ដុល្លារូបនីយកម្មមិនផ្លូវការ (Unofficial Dollarization)

ដុល្លារូបនីយកម្មមិនផ្លូវការ (Unofficial Dollarization) ៖ គឺសំដៅដល់ពេលដែលប្រជាពលរដ្ឋនៃប្រទេសមួយរក្សាទុកទ្រព្យសម្បត្តិរបស់ពួកគេ ជាពិសេសទ្រព្យសកម្មក្នុងទម្រង់ជារូបិយប័ណ្ណបរទេស តាមរយៈការទិញប័ណ្ណបំណុល ឬភាគហ៊ុន ដែលសេដ្ឋវិទូហៅថា ការជំនួសទ្រព្យសកម្ម និងមួយទៀតដែលចាប់ផ្ដើមបញ្ញើ និងសន្សំជារូបិយប័ណ្ណបរទេស ដែលត្រូវបានគេហៅថា ការជំនួសរូបិយវត្ថុ។ បើទោះបីជារូបិយប័ណ្ណនោះមិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ក្នុងការទូទាត់ដោយស្របច្បាប់ក៏ដោយ។ នៅចុងក្រោយដុល្លារូបនីយកម្មមិន

---

[6] Cambonomic Times, "ដុល្លារូបនីយកម្ម", ២៩ ឧសភា ២០២០, https://www.facebook.com/share/zxGNCfvppTiFKHpF/?mibextid=WC7FNe

ផ្លូវការនេះនឹងមានលក្ខណៈដែលថាប្រជាពលរដ្ឋទាំងអស់ចាប់ផ្ដើមគិតតម្លៃទំនិញ និងសេវាជារូបិយប័ណ្ណបរទេស ហើយធ្វើការទូទាត់ជារូបិយវត្ថុក្នុងស្រុកដោយគិតតាមអត្រាប្ដូរប្រាក់ជាក់លាក់មួយ។

ប្រទេសកម្ពុជា ត្រូវបានគេចាត់ទុកថាជាប្រទេសដុល្លារូបនីយកម្មមិនផ្លូវការ ដោយថាតែប្រជាពលរដ្ឋប្រើប្រាស់ប្រាក់បរទេស លាយលំជាមួយប្រាក់រៀល មិនថាជាប្រាក់ដុល្លារអាមេរិក ប្រាក់បាតថៃ និងប្រាក់ដុងវៀតណាមជាដើម បើទោះបីជាមិនមានការទទួលស្គាល់ជាផ្លូវការក៏ដោយ។ លក្ខណៈបែបនេះវានឹងធ្វើឱ្យប្រសិទ្ធិភាពនៃការអនុវត្តគោលនយោបាយរូបិយវត្ថុរបស់ធនាគារ អាចនឹងមិនមានប្រសិទ្ធិភាពទៅលើឧបករណ៍គោលនយោបាយមួយចំនួន ដោយសារតែធនាគារជាតិមិនមានអំណាចនៅក្នុងការគ្រប់គ្រងរូបិយប័ណ្ណបរទេស។

ដោយឡែក ធនាគារជាតិនៃកម្ពុជានាពេលថ្មីៗនេះ បានដាក់ចេញនូវវិធានការប្រមូលយកប្រាក់ដុល្លារអាមេរិកប្រភេទ១$ ២$ និង៥$ ដែលនៅសេសសល់ក្នុងឃ្លាំងយ៉ាងច្រើនរបស់ធនាគារពាណិជ្ជ ដើម្បីបញ្ជូនត្រលប់ទៅប្រទេសដើមវិញ ដែលនេះជាការធ្វើបដិដុល្លារូបនីយកម្មមួយ ក្នុងគោលដៅលើកតម្កើនការប្រើប្រាស់ប្រាក់រៀលក្នុងប្រតិបត្តិការតូចៗឡើងវិញ។

# ជំពូកទី២

# ឥទ្ធិពលនៃដុល្លាូបនីយកម្មមក លើប្រទេសកម្ពុជា

# ជំពូកទី២

# ឥទ្ធិពលនៃដុល្លារូបនីយកម្មមកលើប្រទេសកម្ពុជា

## ២.១. ប្រវត្តិនៃការហូរចូលនៃប្រាក់ដុល្លារ

### ២.១.១. ដំណាក់កាលទី១៖ ការស្តារសេដ្ឋកិច្ចឡើងវិញនៅក្នុងឆ្នាំ១៩៨០

ប្រាក់ដុល្លារចូលក្នុងប្រទេសកម្ពុជាជាលើកដំបូង គឺដើម្បីស្តារសកម្មភាពហិរញ្ញវត្ថុព្រោះប្រទេសនេះបានបាត់បង់ទំនុកចិត្តទៅលើរូបិយវត្ថុរបស់ខ្លួនហើយបានចាប់យកប្រាក់ដុល្លារអាមេរិកមកធ្វើជាមធ្យោយទូទាត់[7]។

នៅពេលដែលប្រទេសនេះ ធ្លាក់ចូលក្នុងរបបខ្មែរក្រហម កាលពី ខែមេសា ឆ្នាំ ១៩៧៥ កម្មវិធីសេដ្ឋកិច្ចបដិវត្តន៍ដ៏ខ្លាំងក្លាមួយត្រូវបានផ្លាស់ប្តូរ។ វារួមមានការលុបបំបាត់លើទីផ្សារ លុបបំបាត់កម្មសិទ្ធឯកជន បំបិតសកម្មភាពសេដ្ឋកិច្ចគ្រប់ប្រភេទ និងសកម្មភាពហិរញ្ញវត្ថុដូចជា ធនាគារហើយសូម្បីតែការប្រើប្រាស់លុយរួមមានទាំងប្រាក់រៀលផងដែរ។ ធនាគារកណ្តាលត្រូវបានបិទ ហើយហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុរបស់ប្រទេសនេះត្រូវបានបំផ្លាញទាំងស្រុង។ ការប្រែប្រួលរ៉ាឌីកាល់នេះបាននាំឱ្យមានអំពើប្រល័យពូជសាសន៍ដែលបណ្តាលឱ្យមនុស្សប្រមាណ ២ លាននាក់ស្លាប់នៅក្នុងប្រទេសកម្ពុជា[8]។

បន្ទាប់ពីរបប ប៉ុល ពត ត្រូវបានដួលរលំនៅឆ្នាំ ១៩៧៩ កម្ពុជាបានប្រឈមនឹងការលំបាកយ៉ាងខ្លាំងក្នុងការស្តារសេដ្ឋកិច្ចសង្គមរបស់ខ្លួនដែលត្រូវបានបំផ្លាញ។ រដ្ឋាភិបាលថ្មីបានអនុម័តរបបនយោបាយសង្គមនិយម ប្រព័ន្ធសេដ្ឋកិច្ចដែលបានគ្រោងទុក។ យុទ្ធសាស្ត្រសេដ្ឋកិច្ចក្នុងអំឡុងទសវត្សឆ្នាំ ១៩៨០ រដ្ឋាភិបាលកម្ពុជាបានផ្តោតលើសកម្មភាពសេដ្ឋកិច្ចសំខាន់ៗចំនួន៣គឺ[9]៖

- ទី១ គឺផ្តោតទៅលើសកម្មភាពសេដ្ឋកិច្ចរបស់រដ្ឋលើផលិតផលខ្នាតធំ និងវិស័យសេដ្ឋកិច្ចសំខាន់ៗផ្សេងទៀត ដូចជា វិស័យហិរញ្ញវត្ថុ និងពាណិជ្ជកម្មជាដើម
- ទី២ គឺសកម្មភាពសេដ្ឋកិច្ចរួមគ្នា សំដៅលើការស្តារវិស័យកសិកម្ម និងការអភិវឌ្ឍ
- ទី៣ គឺសកម្មភាពសេដ្ឋកិច្ច ដូចជាអាជីវកម្មលក់រាយ ហាងលក់ទំនិញខ្នាតតូច សិប្បកម្មធ្វើដោយដៃ និងពាណិជ្ជកម្មតូចតាច។

[7] Sovannroeun Samreth et al, "Development and Structure of Dollarization in Cambodia.", accessed 02 July 2024, https://www.jica.go.jp/english/jica_ri/publication/booksandreports/1517598_24204.html

[8] Luke Hunt, "Cambodia Aims to Reduce Dependency on US Dollar.", 07 March 2021, Cambodia Aims to Reduce Dependency on US Dollar (voanews.com)

[9] Ross, R.1990. "Cambodia: A Country Study. Washington, DC: Library of Congress, Federal Research Division.", accessed 02 July 2024.

ទន្ទឹមនឹងនេះ ធនាគារជាតិនៃកម្ពុជា (NBC) ត្រូវបានស្តារឡើងវិញជាធនាគារកណ្តាលនៃកម្ពុជាហើយបានចាប់ផ្តើមចេញបោះពុម្ពប្រាក់រៀលសារជាថ្មី។ ធនាគារពាណិជ្ជបរទេសបានបន្តផ្តល់នូវសេវាធនាគារពាណិជ្ជ ដែលធនាគារនេះគ្រប់គ្រងទាំងស្រុងដោយរដ្ឋាភិបាល។ ទោះបីជាប្រព័ន្ធហិរញ្ញវត្ថុ និងសេដ្ឋកិច្ចរូបិយវត្ថុត្រូវបានស្តារឡើងវិញក៏ដោយ ក៏ការអភិវឌ្ឍសកម្មភាពហិរញ្ញវត្ថុនៅមានកម្រិតនៅឡើយ ដោយសារអស្ថិរភាពនយោបាយ ការរាំងស្ទះសេដ្ឋកិច្ចក្រោមគោលនយោបាយសេដ្ឋកិច្ចសង្គមនិយម និងខ្វះការទុកចិត្តលើរូបិយប័ណ្ណថ្មី។ ខណៈដែលទំនុកចិត្តទៅលើរូបិយប័ណ្ណថ្មីនេះមិនបានកើនឡើង ប្រាក់ដុល្លារត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយជាមធ្យោបាយនៃការដោះស្រាយជំនួញ និងការរក្សាទុកតម្លៃ។ ទោះជាយ៉ាងណាក៏ដោយ ចាប់តាំងពីការប្រើប្រាស់ប្រាក់ដុល្លារត្រូវបានកំណត់នៅក្រោមប្រព័ន្ធហិរញ្ញវត្ថុសង្គមនិយម ប្រាក់ដុល្លារនេះត្រូវបានប្រើប្រាស់នៅក្នុងរូបភាពជាសាច់ប្រាក់តែប៉ុណ្ណោះ។ ដោយឡែក ការធ្វើពាណិជ្ជកម្មពីបរទេសមានភាពយឺតយ៉ាវ ហើយការហូរចូលនៃមូលនិធិក្រៅប្រទេសមកលើកម្ពុជានៅមានភាពទន់ខ្សោយក្នុងទសវត្សឆ្នាំ ១៩៨០ ដូច្នេះហើយ ចំនួនប្រាក់ដុល្លារដែលបានចរាចរនោះនៅមានកម្រិត[10]។

**២.១.២.ដំណាក់កាលទី២៖ ក្រោយការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស**

នៅក្នុងដំណាក់កាលទីពីរនេះ សេដ្ឋកិច្ចទូទាំងប្រទេសត្រូវបានស្តារឡើងវិញ ហើយការចរាចរប្រាក់ដុល្លារមានការកើនឡើងក្នុងចំណោមសាធារណជន និងនៅពីក្រោយគោលបំណងហិរញ្ញវត្ថុនៅទសវត្សឆ្នាំ ១៩៩០ ការហូរចូលដ៏ធំនៃប្រាក់ដុល្លារដែលភាគច្រើនបានមកពីលំហូរនៃជំនួយ ទើបធ្វើឱ្យមានការធ្លាក់ចុះនៃប្រាក់រៀល។ ប្រទេសកម្ពុជាបានក្លាយជាប្រព័ន្ធសេដ្ឋកិច្ចនយោបាយ និងទីផ្សាររបស់គណបក្សចម្រុះ ហើយធ្វើការផ្លាស់ប្តូរប្រព័ន្ធនយោបាយ និងសេដ្ឋកិច្ចរបស់ខ្លួនចាប់ពីដើមទសវត្សឆ្នាំ ១៩៩០[11]។

បន្ទាប់ពីការចរចាច្រើនលើកច្រើនសារ កិច្ចព្រមព្រៀងសន្តិភាពមួយត្រូវបានចុះហត្ថលេខានៅឆ្នាំ ១៩៩១ នៅទីក្រុងប៉ារីស ប្រទេសបារាំង។ នៅដើមទសវត្សឆ្នាំ ១៩៩០ ជារយៈពេលនៃការផ្លាស់ប្តូរសម្រាប់កម្ពុជា។ ការបោះឆ្នោតទូទៅលើកទី១បានធ្វើឡើងនៅឆ្នាំ ១៩៩៣ ដោយមានជំនួយពីអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិ (UNTAC)។ ក្រោយការបោះឆ្នោតលើកដំបូង កម្ពុជាបានក្លាយជាប្រទេសប្រជាធិបតេយ្យ

[10] Samreth Sovannroeun and Okuda Hidenobu, “Economic Growth and Dollarization in Cambodia.”, 01 January 2019, アジア研究 (jst.go.jp)

[11] Sovannroeun Samreth et al, “Development and Structure of Dollarization in Cambodia.”, accessed 02 July 2024, https://www.jica.go.jp/english/jica_ri/publication/booksandreports/1517598_24204.html.

អាស្រ័យរដ្ឋធម្មនុ[12]។ ប្រទេសកម្ពុជាបានអនុម័តនយោបាយប្រជាធិបតេយ្យប្រព័ន្ធសេដ្ឋកិច្ចពហុបក្ស និងប្រព័ន្ធសេដ្ឋកិច្ចបែបទីផ្សារសេរី។ ភារកិច្ចសំខាន់បំផុតរបស់រដ្ឋាភិបាលថ្មី គឺការសាងសង់ប្រទេសក្រោយសង្គ្រាមឡើងវិញ។ ដូច្នេះលោកបានអនុម័តផែនការស្តារសេដ្ឋកិច្ចសង្គមមួយនៅឆ្នាំ ១៩៩១ បន្ទាប់ពីការស្នើសុំផែនការគោលនយោបាយផ្សេងៗ សម្រាប់ការបង្កើនការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ ផែនការគោលនយោបាយទាំងនេះ រួមមានយុទ្ធសាស្ត្រត្រីកោណឆ្នាំ ១៩៩៨ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ ឆ្នាំ២០០៤ ដំណាក់កាលទី២ ឆ្នាំ ២០០៨ និងដំណាក់កាលទី៣ យុទ្ធសាស្ត្រចតុកោណឆ្នាំ២០១៣[13]។

ក្នុងអំឡុងពេលនៃការផ្លាស់ប្តូរឆ្ពោះទៅរកការបោះឆ្នោតលើកដំបូងរបស់ខ្លួននៅឆ្នាំ ១៩៩៣ កម្ពុជាបានជួបប្រទះនូវអតិផរណាខ្ពស់ និងការធ្លាក់ចុះយ៉ាងលឿន នៅក្នុងរូបិយវត្ថុរបស់ខ្លួនគឺប្រាក់រៀល។ អត្រាប្តូរប្រាក់មានតែនាមធៀបនឹងប្រាក់ដុល្លារអាមេរិកបានកើនឡើងពី ៥០០រៀល ក្នុងមួយដុល្លារអាមេរិកទៅ ២០០០ រៀលក្នុងមួយដុល្លារអាមេរិក ចន្លោះឆ្នាំ១៩៩១ និងឆ្នាំ១៩៩២[14]។ ភាពមិនប្រាកដប្រជានៃផ្នែកនយោបាយ បានជះឥទ្ធិពលយ៉ាងខ្លាំងមកលើសាធារណជន។ អស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងភាពមិនប្រាកដប្រជាផ្នែកនយោបាយបែបនេះ បានរួមចំណែកដល់ការថយចុះនៃទំនុកចិត្តរបស់សាធារណជនទៅលើប្រាក់រៀល ដែលនាំឱ្យមានចំណង់ចំណូលចិត្តក្នុងការកាន់រូបិយប័ណ្ណបរទេស និងទ្រព្យសកម្មជាក់ស្តែងផ្សេងទៀត (ឧទាហរណ៍ ៖ មាស និងស្រូវ )។

មួយទៀតកត្តាដែលធ្វើឱ្យមានការកើនឡើងនៃប្រាក់ដុល្លារ ក្នុងអំឡុងដើមទសវត្សឆ្នាំ ១៩៩០ គឺការហូរចូលដ៏ធំនៃហិរញ្ញវត្ថុខាងក្រៅដែលប្រើសម្រាប់ប្រតិបត្តិការរបស់ UNTAC និងរដ្ឋាភិបាលកម្ពុជាដែលទើបបង្កើតថ្មី។ តម្លៃនៃការបោះឆ្នោតទូទៅលើកទី១ ត្រូវបានប៉ាន់ប្រមាណជា ១,៧ ពាន់លានដុល្លារអាមេរិក ឬប្រហែល ៧៥% នៃផលិតផលក្នុងស្រុកសរុប (GDP) របស់កម្ពុជានៅឆ្នាំ ១៩៩៣[15]។ រដ្ឋាភិបាលថ្មីបានបន្តខ្ចីប្រាក់ពីបរទេស ដើម្បីទប់ទៅនឹងឱនភាពថវិការបស់ខ្លួន។ មូលនិធិភាគច្រើនដែលហូរចូលទៅក្នុងប្រទេស គឺស្ថិត

[12] Samreth Sovannroeun and Okuda Hidenobu, “Economic Growth and Dollarization in Cambodia.”, 01 January 2019, アジア研究 (jst.go.jp)

[13] Kuoch, S., and S. Samreth, “Labour Force and Labour Market in Cambodia: Facts, Challenges and Policy Actions.” In Human resource Landscape in Mainland ASEAN, edited by S. Bunnag, and P. Srisangnam, 1-23. Bangkok: Chulalongkorn University Press., 2020.

[14] Zamaróczy, M., and S. Sa., “Economic Policy in a Highly Dollarized Economy: The Case of Cambodia.”, Washington, DC: International Monetary Fund, 2002.

[15] Lay, S., M. Kakinaka, and K. Kotani, “Exchange Rate Movement in Dollarized Economy.” ASEAN Economic Bulletin 29 (1): 65-78, 2012.

នៅក្នុងរូបភាពជារូបិយប័ណ្ណបរទេស និងត្រូវបានប្រើប្រាស់ដើម្បីទូទាត់សកម្មភាពជំនួយ និងការចំណាយរបស់រដ្ឋាភិបាលហើយមូលនិធិរូបិយប័ណ្ណបរទេសបានបន្តកើនឡើង[16]។

ការបាត់បង់ការទុកចិត្តលើរូបិយប័ណ្ណក្នុងស្រុក និងការរីករាលដាលរូបិយបណ្ណ័បរទេសនៅក្នុងសេដ្ឋកិច្ច បាននាំឱ្យមានការពង្រីកបន្ថែមទៀតនូវការកាន់កាប់ប្រាក់ដុល្លារជាមធ្យោបាយនៃការទូទាត់ឯកតានៃគណនី និងការរក្សាទុកតម្លៃនៅកម្ពុជា ដូចដែលបានបង្ហាញដោយ លោក Kang[17]។

### ២.១.៣. ដំណាក់កាលទី៣៖ ចាប់តាំងពីឆ្នាំ២០០០

នៅក្នុងឆ្នាំ ២០០០ ប្រទេសកម្ពុជាទទួលបានស្ថិរភាពនយោបាយ និងសេដ្ឋកិច្ចនៃស្ថាប័នហិរញ្ញវត្ថុ ដូចជាធនាគារពាណិជ្ជ ហើយមានការអភិវឌ្ឍយ៉ាងឆាប់រហ័ស ទោះបីជាយ៉ាងណាក៏ដោយកម្ពុជានៅតែមានការចរាចរប្រាក់ដុល្លារកាន់តែខ្ពស់ នេះគឺដោយសារការបង្កើតឥណទានក្រោមរូបភាពជាប្រាក់ដុល្លារ។ សេដ្ឋកិច្ចកម្ពុជាមានការកើនឡើងគួរឱ្យកត់សម្គាល់ចាប់តាំងពីការចូលទៅក្នុងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN) នៅឆ្នាំ ១៩៩៩។ ការនាំចេញសម្លៀកបំពាក់ទៅទីផ្សារភាគខាងលិច និងសកម្មភាពក្នុងស្រុកផ្សេងៗជាផ្នែកមួយដែលជំរុញឱ្យមានកំណើនសេដ្ឋកិច្ច។ នៅពីក្រោយកំណើនសេដ្ឋកិច្ច និងស្ថិរភាពនយោបាយនេះ ដោយសារតែការហូរចូលរូបិយប័ណ្ណបរទេសមានការកើនឡើងជាលំដាប់ តាមរយៈការនាំចេញ និងការវិនិយោគផ្ទាល់ពីបរទេស និងលំហូរជំនួយផ្សេងៗទៀត ។

ចាប់តាំងពីចុងទសវត្សឆ្នាំ ១៩៩០ មកកម្ពុជាបានកំពុងអភិវឌ្ឍន៍ប្រព័ន្ធហិរញ្ញវត្ថុរបស់ខ្លួនយ៉ាងសកម្ម។ កំណែទម្រង់ហិរញ្ញវត្ថុ ត្រូវបានអនុវត្តន៍ក្រោមគោលនយោបាយនៃការកាត់បន្ថយភាពជាម្ចាស់របស់ធនាគារ និងអន្តរាគមន៍ ទីផ្សារពីរដ្ឋាភិបាល។ មិនខុសពីចិន វៀតណាម និងឡាវ ដែលជាប្រទេសមានការផ្លាស់ប្តូរប្រព័ន្ធសេដ្ឋកិច្ចដែរ តែវិស័យហិរញ្ញវត្ថុគឺជារបស់ឯកជន។

ចំណែកធនាគារពាណិជ្ជត្រូវបានបង្កើតឡើង តាមរយៈការបណ្តាក់ទុនរួមគ្នាជាមួយមូលធនឯកជនបរទេស[18]។ នៅក្នុងឆ្នាំ ២០០០ ធនាគារ និងគ្រឹះស្ថានមិនមែនជាធនាគារបានបង្កើនទន់វិនិយោគរបស់ខ្លួនដោយការខ្ចីប្រាក់ពីបរទេស និងការបោះទុនវិនិយោគពីក្រៅប្រទេសក្នុងរូបភាពជាប្រាក់ដុល្លារ ដែលធ្វើឱ្យកម្ចីឥណទាន

[16] International Monetary Fund, “Cambodia: Staff Report for the 2010 Article IV Consultation.”, Washington, DC: International Monetary Fund, 2011.

[17] Kang, K., “Is Dollarization Good for Cambodia?” Global Economic Review 34(2): 201-211, 2005.

[18] Unteroberdoerster, O., “Banking Reform in the Lower Mekong Countries.”, Washington, DC: International Monetary Fund, 2004.

ជាប្រាក់ដុល្លារនៅកម្ពុជាមានការកើនឡើង[19]។ លំហូរនៃប្រាក់ដុល្លារនៅកម្ពុជា មានការចាយវាយក្នុងទម្រង់ជាក្រដាសប្រាក់ និងមួយផ្នែកទៀតជាកម្ចីឥណទានពីធនាគារ។

ដូច្នេះហើយ បានជាប្រាក់ដុល្លារនៅកម្ពុជាមានភាពរីកដុះដាលយ៉ាងឆាប់រហ័ស។ ទោះបីជាប្រាក់ដុល្លារបានជួយធ្វើឱ្យកម្ពុជាមានស្ថេរភាពផ្នែកសេដ្ឋកិច្ច ហើយការពឹងផ្អែកទៅលើប្រាក់ដុល្លាររឹតតែខ្ពស់ចាប់តាំងពីឆ្នាំ ២០០០ មកម្លេះ។

## ២.២. ការវិវត្តន៍នៃប្រាក់ដុល្លារមកលើស្ថានភាពប្រទេសកម្ពុជា

ការលេចចេញរូបិយប័ណ្ណនីយកម្មនៅកម្ពុជា អាចបណ្តាលមកពីការបាត់បង់ទំនុកចិត្តពីសាធារណជនចំពោះរូបិយប័ណ្ណជាតិប្រាក់រៀល។ ការបាត់បង់ទំនុកចិត្តនេះកើតចេញពីភាពតក់ស្លុតជាបន្តបន្ទាប់ រួមទាំងការបំផ្លិចបំផ្លាញដែលបង្កឡើងដោយខ្មែរក្រហម និងការគ្រប់គ្រងសេដ្ឋកិច្ចមិនត្រឹមត្រូវជាបន្តបន្ទាប់។ ការខ្វះជំនឿលើស្ថាប័ន និងប្រព័ន្ធធនាគារនៅតែមានកម្រិតខ្ពស់ ដែលនាំទៅដល់ដំណើរការបន្តនៃរូបិយប័ណ្ណនីយកម្ម ទោះបីជាមានភាពប្រសើរឡើងនៃស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងការខិតខំប្រឹងប្រែងរបស់អាជ្ញាធរដើម្បីស្តារទំនុកចិត្តឡើងវិញក៏ដោយ។ ប្រាក់ដុល្លារក្នុងប្រទេសកម្ពុជាអាចត្រូវបានគេមើលឃើញថា ជាការឆ្លើយតបទៅនឹងចំណុចកំពូលនៃភាពតក់ស្លុត បទពិសោធន៍ និងព្រឹត្តិការណ៍ដែលបំផ្លាញទំនុកចិត្តសាធារណៈ លើសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការរក្សាតម្លៃប្រាក់រៀល។

ទោះបីជារដ្ឋាភិបាលកម្ពុជា មិនដែលបានអនុម័តជាផ្លូវការនូវរូបិយប័ណ្ណនីយកម្មក៏ដោយ ក៏កម្ពុជាបានក្លាយជាប្រទេសមួយដែលមានសេដ្ឋកិច្ចដុល្លារច្រើនជាងគេនៅលើពិភពលោក។ ប្រាក់ដុល្លារអាមេរិកត្រូវបានប្រើប្រាស់មិនត្រឹមតែសម្រាប់ប្រតិបត្តិការពាណិជ្ជកម្មប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់ប្រតិបត្តិការប្រចាំថ្ងៃផងដែរ។

## ២.៣. ប្រព័ន្ធម៉ាក្រូសេដ្ឋកិច្ច និងដុល្លារូបនីយកម្ម

### ២.៣.១ កំណើនសេដ្ឋកិច្ច

ក្នុងកំឡុងទសវត្សរ៍ឆ្នាំ ១៩៨០ គឺជារយៈពេលមួយដែលសេដ្ឋកិច្ចរបស់ប្រទេសមានការអន់ថយ ប៉ុន្តែចាប់ពីទសវត្សរ៍ឆ្នាំ ១៩៩០ ដល់ឆ្នាំ ២០១០ គឺជារយៈពេលនៃការងើបឡើងវិញនៃសេដ្ឋកិច្ច និងសន្ទុះនៃកំណើនផ្សេងៗក្នុងប្រទេសកម្ពុជា។ តារាងទី១ បង្ហាញពីអត្រាកំណើនប្រចាំឆ្នាំ ជាមធ្យមនៃផលិតផលក្នុងស្រុកសរុបមនុស្សម្នាក់ៗនៅកម្ពុជា នៅប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងៗ និងនៅក្នុងពិភពលោក ក្នុងរយៈពេលខុសៗគ្នាចន្លោះ

[19] Khou, V., "Cambodia's Monetary Policy: Dollarization, Managing National Currency Supply and Exchange Rate Stability.", Paper presented at the Conference of the Japan Association of Asian Studies, Keio University, 31 May 2014.

ពីឆ្នាំ ១៩៩៥ និង ២០១៩ ។ តាមរយៈតារាងអត្រាកំណើនជាមធ្យមនៅកម្ពុជាគឺ ខ្ពស់ជាងអត្រាកំណើនជាមធ្យមរបស់ប្រទេសកំពុងអភិវឌ្ឍន៍នានា និងពិភពលោក។ ពិសេសជាងនេះទៅទៀត ក្នុងទសវត្សរ៍ឆ្នាំ ១៩៩៥ (១៩៩៥-១៩៩៩) អត្រាកំណើនជាមធ្យមនៃផលិតផលក្នុងស្រុកសរុបក្នុងមនុស្សម្នាក់នៅប្រទេសកម្ពុជាមានប្រហែល ៤.៤% ខណៈដែលអត្រាកំណើនប្រចាំឆ្នាំ ជាមធ្យមសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍មាន ប្រហែល ២.១% (តារាងទី១)។ កំណើនសេដ្ឋកិច្ចរបស់កម្ពុជានឹងខ្ពស់ជាងនេះ ប្រសិនបើមិនបណ្តាលមកពីផលប៉ះពាល់អវិជ្ជមាននៃវិបត្តិហិរញ្ញវត្ថុអាស៊ី និងជម្លោះផ្ទៃក្នុងនានា។

**តារាងទី១** ៖ អត្រាកំណើនផលិតផលក្នុងស្រុកសរុប គិតជាមធ្យមក្នុងមនុស្សម្នាក់[20]

*Table 1.1* Average GDP per capita growth rates (%) in Cambodia and selected groups

| *Period* | *Cambodia* | *Developing countries* | *World* |
|---|---|---|---|
| 1995–1999 | 4.4 | 2.1 | 1.7 |
| 2000–2009 | 6.6 | 4.4 | 1.6 |
| 2010–2019 | 5.4 | 3.7 | 1.8 |
| **1995–2019** | **5.7** | **3.6** | **1.7** |

**ប្រភព** ៖ World Development Indication, World Bank (2021a)

ក្នុងកំឡុងទសវត្សរ៍ឆ្នាំ ២០០០ (២០០០ - ២០០៩) គឺជាកំឡុងពេលមួយដែលសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាចាប់ផ្តើមមានភាពល្អប្រសើរ។ សង្គ្រាមស៊ីវិលដែលបានកើតឡើងជិតបីទសវត្សរ៍បានបញ្ចប់ទាំងស្រុងក្នុងឆ្នាំ ១៩៩៨ នៅពេលដែលអតីតក្រុមខ្មែរក្រហមដែលនៅសេសសល់បានដួលរលំ។ ហើយទោះបីជាត្រូវបានរំខានដោយវិបត្តិហិរញ្ញវត្ថុពិភពលោក ក្នុងឆ្នាំ ២០០៨ និង ២០០៩ ក៏ដោយ ក៏អត្រាកំណើនជាមធ្យមនៃផលិតផលក្នុងស្រុកសរុបរបស់កម្ពុជា ក្នុងមនុស្សម្នាក់ក្នុងទសវត្សរ៍ឆ្នាំ ២០០០ មានប្រហែល ៦.៦% (តារាងទី១)។ អត្រាកំណើននេះគឺ ខ្ពស់ជាងប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀត និងក្នុងពិភពលោកជាទូទៅ។ ចាប់ពីទសវត្សរ៍ឆ្នាំ ២០១០ អត្រាកំណើនប្រចាំឆ្នាំ ជាមធ្យមនៃផលិតផលក្នុងស្រុកសរុបក្នុងមនុស្សម្នាក់នៅកម្ពុជាក៏មានកម្រិតខ្ពស់ផងដែរគឺ ប្រហែល ៥.៤% ចន្លោះឆ្នាំ ២០១០ ដល់ឆ្នាំ ២០១៩។

ជារួមចាប់តាំងពីការផ្លាស់ប្តូរទៅជាសេដ្ឋកិច្ចទីផ្សារសេរីនៅដើមទសវត្សរ៍ឆ្នាំ ១៩៩៥ មកប្រទេសកម្ពុជាទទួលបានកំណើនសេដ្ឋកិច្ចខ្ពស់គួរឱ្យកត់សម្គាល់។ សមិទ្ធិផលនេះបានធ្វើឱ្យប្រទេសកម្ពុជា ដែលធ្លាប់ជា

[20] Developing countries refer to the group of low- and middle- income countries.

ប្រទេសដែលមានចំណូលកម្រិតទាបទៅ ជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបក្នុងឆ្នាំ ២០១៥[21] ។ កំណើនសេដ្ឋកិច្ចក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៩០ ដល់ឆ្នាំ ២០១០ កម្រិតជីវភាពរបស់ប្រជាជនកម្ពុជាក៏មានភាពប្រសើរឡើងយ៉ាងខ្លាំងផងដែរ។ ប្រាក់ចំណូលជាតិសរុប (GNI) របស់កម្ពុជាក្នុងមនុស្សម្នាក់បានកើនឡើងពី ២៥០ ដុល្លារក្នុងឆ្នាំ ១៩៩៥ ដល់ ១៥៣០ ដុល្លារក្នុងឆ្នាំ ២០១៩ នេះបើយោងតាមទិន្នន័យពីធនាគារពិភពលោក[22]។

### ២.៣.២. ការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច

នៅក្នុងដំណើរការនៃកំណើនសេដ្ឋកិច្ច ទោះបីជាមាន ឬមិនមានការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចកើតឡើងក៏ដោយ ក៏ការផ្លាស់ប្តូរទាំងនេះមានសារៈសំខាន់ខ្លាំងណាស់ដែរនៅក្នុងសេដ្ឋកិច្ច។ កំណើនសេដ្ឋកិច្ចដែលមិនមានការផ្លាស់ប្តូររចនាសម្ព័ន្ធ មិនអាចធ្វើឱ្យកម្រិតជីវភាពរបស់ប្រជាជនមួយភាគធំប្រសើរឡើងនោះទេ ហើយអាចបង្កើនវិសមភាពប្រាក់ចំណូលបន្ថែមទៀតផង។ យោងតាមការពិភាក្សារបស់លោក Kuoch និង Samreth[23] ប្រទេសកម្ពុជា គឺដូចជាប្រទេសគំរូនៃកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍនៅក្នុងប្រទេសក្នុងតំបន់ផ្សេងទៀត កំណើនសេដ្ឋកិច្ចនៅចន្លោះទសវត្សរ៍ឆ្នាំ ១៩៩០ រហូតដល់ឆ្នាំ ២០១០ ត្រូវបានធ្វើការផ្លាស់ប្តូររចនាសម្ព័ន្ធទាំងផ្នែកសេដ្ឋកិច្ច និងរចនាសម្ព័ន្ធការងារ។ សេដ្ឋកិច្ចកម្ពុជាធ្លាប់តែភាគច្រើនពឹងផ្អែកលើផលិតកម្មកសិកម្ម បានធ្វើការផ្លាស់ប្តូរទៅជាផលិតកម្មផ្អែកលើឧស្សាហកម្ម។ ក្រាហ្វិកទី១ បង្ហាញពីចំណែកនៃវិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្មជាផលិតផលក្នុងស្រុកសរុបរបស់ប្រទេសកម្ពុជាចន្លោះឆ្នាំ ១៩៩៥ និង ២០១៩ ។ តួលេខនេះបង្ហាញពីការកំណើននៃវិស័យឧស្សាហកម្ម និងការធ្លាក់ចុះនៃចំណែកកសិកម្មនៅក្នុងសេដ្ឋកិច្ច។ តាមក្រាហ្វិកទី១ វិស័យកសិកម្មបានថយចុះប្រហែលពី ៤៨% ក្នុងឆ្នាំ ១៩៩៥ មកនៅប្រហែល ២១% ក្នុងឆ្នាំ ២០១៩។

[21] ប្រាក់ចំណូលជាតិសរុបរបស់កម្ពុជា (GNI) ក្នុងមនុស្សម្នាក់ក្នុងឆ្នាំ 2015 មានចំនួន 1,060 ដុល្លារអាមេរិក ដែលនេះគឺខ្ពស់ជាងកម្រិតអប្បបរមា GNI ក្នុងមនុស្សម្នាក់ (1,025 ដុល្លារអាមេរិក) របស់ក្រុមចំណូលមធ្យមកម្រិតទាបដែលយោងតាមធនាគារពិភពលោក

[22] World Bank, "World Development Indicators.", Washington, DC: World Bank, 2021a, https://data.worldbank.org/products/wdi

[23] Kuoch, S., and S. Samreth "Labour Force and Labour Market in Cambodia: Facts, Challenges and Policy Actions.", In Human Resource Landscape in Mainland ASEAN, edited by S. Bunnay, and P. Srisangnam, 1-23. Bangkok: Chulalongkorn University Press, 2020.

**ក្រាហ្វិកទី១** ៖ បម្រែបម្រួលផលិតផលក្នុងស្រុកនៅក្នុងវិស័យនីមួយៗ




*Figure 1.1* Value-added shares in GDP by sector between 1995 and 2019

**ប្រភព** ៖ World Development Indicators, World Bank（2021a）

ការផ្លាស់ប្ដូររចនាសម្ព័ន្ធគួរឱ្យកត់សម្គាល់ នៅផ្នែកការងារនៅក្នុងប្រទេសកម្ពុជា គឺពីការងារក្នុងវិស័យកសិកម្មដែលធ្លាប់តែមានតម្រូវការការងារខ្ពស់ ប្រែទៅជាមានតម្រូវការផ្នែកសេវាកម្ម និងឧស្សាហកម្មនៅចន្លោះទសវត្សរ៍ឆ្នាំ ១៩៩០ និងឆ្នាំ២០១០ ដូចដែលបានបង្ហាញនៅក្នុងក្រាហ្វិកទី២។ តាមក្រាហ្វិកទី២ចំណែកនៃការងារក្នុងវិស័យកសិកម្មបានធ្លាក់ចុះពីប្រហែល ៥៧% ក្នុងឆ្នាំ ២០១០ មកនៅប្រហែល ៣៥% ក្នុងឆ្នាំ ២០១៩។ ការធ្លាក់ចុះនេះត្រូវបានជំនួសមកវិញដោយការកើនឡើងគួរឱ្យកត់សម្គាល់ នៃការងារទាំងក្នុងវិស័យឧស្សាហកម្ម និងសេវាកម្ម។ ទោះបីជាមានការផ្លាស់ប្ដូររចនាសម្ព័ន្ធនៅក្នុងវិស័យសេដ្ឋកិច្ច និងការផ្លាស់ប្ដូរចំណែកការងារនៅក្នុងប្រទេសកម្ពុជាឲ្យឆ្ពោះទៅរកផ្នែកឧស្សាហកម្មកាន់តែច្រើនក៏ដោយ គួរឱ្យកត់សម្គាល់ដែរថាផលិតផលដែលទាក់ទងនឹងសម្លៀកបំពាក់ និងស្បែកជើងនៅតែមានចំណែកខ្ពស់ក្នុងវិស័យផលិតកម្ម។ តម្លៃបន្ថែមពីវិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងមានចំនួនប្រហែល ១១% នៃទិន្នផលសរុបនៅក្នុងប្រទេសកម្ពុជា និង ៧៤% នៃការនាំចេញទំនិញសរុបគឺជាផលិតផលកាត់ដេរ និងស្បែកជើងក្នុងឆ្នាំ ២០១៨[24]។ មិនតែប៉ុណ្ណោះសកម្មភាពទាក់ទងនឹងវិស័យទេសចរណ៍ក៏មានការរីកចម្រើនផងដែរ។

[24] International Labour Organization, "The Footwear Sector: New Opportunities for Cambodia？", Cambodia Garment and Footwear Sector Bulletin 9, 2019.

**ក្រាហ្វិកទី២** ៖ បំណែកការងារតាមវិស័យនីមួយៗ



*Figure 1.2* Employment shares by sector between 1995 and 2019

**ប្រភព** ៖ World Development Indicators, World Bank (2021a)

## ២.៤. ការវិនិយោគផ្ទាល់ពីបរទេស និងជំនួយពីបរទេស

បន្ទាប់ពីការបោះឆ្នោតលើកដំបូងជាសកល រដ្ឋាភិបាលថ្មីរបស់កម្ពុជាត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៣។ សមពេលជាមួយគ្នានេះ ទណ្ឌកម្មសេដ្ឋកិច្ចដែលបានដាក់មកលើប្រទេសកម្ពុជាក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៨០ ត្រូវបានលើកលែង[25]។ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ប្រទេសកម្ពុជាត្រូវបានកត់សម្គាល់ដោយលំហូរយ៉ាងលឿននៃជំនួយបរទេស និងការវិនិយោគផ្ទាល់ពីបរទេស ដោយសារគោលនយោបាយសេដ្ឋកិច្ច បើកចំហរបស់រដ្ឋាភិបាលថ្មីដែលត្រូវបានអនុម័តយ៉ាងសកម្ម។ ក្រាហ្វិកទី៣ បង្ហាញពីចំណែកនៃជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) និង ជំនួយផ្លូវការផ្សេងទៀត និងលំហូរ FDI ចូលមកកម្ពុជាចន្លោះឆ្នាំ ១៩៩៣ និង ២០១៩ ។

**ក្រាហ្វិកទី៣** ៖ ចំណែកនៃជំនួយអភិវឌ្ឍន៍ផ្លូវការ និងការវិនិយោគផ្ទាល់ពីបរទេស



*Figure 1.3* Structure of effective demand (% of GDP at current market prices)

**ប្រភព** ៖ World Development indicators, World Bank (2021a)

25 Hang, C., "The Cambodian Economy: Charting the Course of a Brighter Future.", Singapore: Institute of Southeast Asian Studies, 2012.

ដូចដែលបានបង្ហាញនៅក្នុងក្រាហ្វិកទី៣ ចំណែកនៃជំនួយបរទេសមានចំនួនជាង ១០% នៃផលិតផលក្នុងស្រុកសរុបរបស់កម្ពុជាក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៩០[26]។ ក្នុងអំឡុងពេលនោះ ក្នុងចំណោមប្រទេសនៃគណៈកម្មាធិការជំនួយអភិវឌ្ឍន៍ (DAC) របស់អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD) មានប្រទេសជប៉ុន សហរដ្ឋអាមេរិក និងអូស្ត្រាលី គឺជាអ្នកផ្តល់ជំនួយទ្វេភាគីឈានមុខគេដល់កម្ពុជា។ ចាប់ពីដើមទសវត្សរ៍ឆ្នាំ ២០០០ កូរ៉េខាងត្បូង និងចិនក៏ជាប្រទេសម្ចាស់ជំនួយសំខាន់ដល់កម្ពុជា។ ចំណែកជំនួយពីកូរ៉េខាងត្បូងមានច្រើនជាង១០% នៃជំនួយសរុបពីប្រទេសគណៈកម្មាធិការជំនួយអភិវឌ្ឍន៍អស់រយៈពេលជាច្រើនឆ្នាំចាប់ពីដើមទសវត្សរ៍ឆ្នាំ២០១០[27]។

កម្ពុជាក៏បានទទួលជំនួយអភិវឌ្ឍន៍ផ្លូវការពីប្រទេសចិនជាង ៣ ពាន់លានដុល្លារអាមេរិក រហូតដល់ឆ្នាំ ២០១៤ នេះបើយោងតាមទិន្នន័យជំនួយដែលចេញផ្សាយដោយវិទ្យាស្ថានសម្រាប់ទ្រឹស្តី និងការអនុវត្តទំនាក់ទំនងអន្តរជាតិនៅមហាវិទ្យាល័យ William and Mary[28] ។ សម្រាប់ម្ចាស់ជំនួយពហុភាគីស្ថាប័នអន្តរជាតិមានដូចជាធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី ក៏ជាស្ថាប័នឈានមុខគេដែលផ្តល់ជំនួយដល់ប្រទេសកម្ពុជាផងដែរ។ ជំនួយពីបរទេសដល់កម្ពុជា ត្រូវបានប្រើប្រាស់ជាចម្បងសម្រាប់ការស្តារសេដ្ឋកិច្ចសង្គម និងការលើកកម្ពស់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍជំនួសទាំងនោះត្រូវបានប្រើប្រាស់សម្រាប់ការសាងសង់ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធដែលជួយលើកកម្ពស់សកម្មភាពសេដ្ឋកិច្ចក្នុងស្រុក និងធ្វើឱ្យប្រសើរឡើងនូវការតភ្ជាប់រវាងប្រទេសកម្ពុជា និងប្រទេសជិតខាង[29]។ ទោះជាយ៉ាងណាក៏ដោយ វាក៏ជារឿងសំខាន់ដែលត្រូវកត់សម្គាល់ថា លំហូរជំនួយបរទេសចូលមកក្នុងប្រទេសកម្ពុជាគិតជាភាគរយនៃផលិតផលក្នុងស្រុកសរុបបានធ្លាក់ចុះ ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ ២០០០ ខណៈដែលលំហូរចូលការវិនិយោគពីបរទេសជាភាគរយនៃផលិតផលក្នុងស្រុកសរុបបានកើនឡើង។ និន្នាការផ្ទុយគ្នាទាំងនេះមិនគួរភ្ញាក់ផ្អើលទេ ដោយសារការពិតដែលថានៅពេលដែលប្រទេសមួយមានការអភិវឌ្ឍ វាជារឿងធម្មតាសម្រាប់ការវិនិយោគផ្ទាល់ពីបរទេសកើនឡើង ខណៈពេលដែលជំនួយពីបរទេសធ្លាក់ចុះ។

[26] Godfrey et al. (2002), among others, provide a good discussion on the role and impacts of foreign aid on the Cambodian socioeconomic situation.

[27] World Bank, "World Development Indicators.", Washington, DC: World Bank, 2021a, https://data.worldbank.org/products/wdi

[28] www.aiddata.org/china

[29] Among others, the Kizuna Bridge and the Tsubasa Bridge were constructed through a grant aid from Japan. These bridges help boost the transportation network between Cambodia, Vietnam, and Thailand as part of Southern Economic Corridor network.

បើធ្វើការក្រឡេកមើលការវិនិយោគផ្ទាល់ពីបរទេសឱ្យកាន់តែលម្អិត យើងឃើញថាជំនួយពីបរទេសបានធ្វើឱ្យក្រាហ្វិកនៃផលិតផលក្នុងស្រុកមានការកើនឡើងខ្ពស់គួរឱ្យកត់សម្គាល់ ទោះបីជានៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ មានការប្រែប្រួលដោយសារតែការរំខានដោយនយោបាយមិនមានស្ថិតស្ថេរក៏ដោយ ប៉ុន្តែយើងក៏ឃើញមានកើនឡើងមកវិញ យ៉ាងឆាប់រហ័សពីដើមទសវត្សរ៍ឆ្នាំ ២០០០។ ក្នុងចំណោមកត្តាផ្សេងទៀតដែលរួមចំណែកដល់និន្នាការនេះគឺតួនាទីសំខាន់នៃស្ថិរភាពនយោបាយដែលទាក់ទងទៅនឹងការបញ្ចប់នៃសង្គ្រាមស៊ីវិលក្នុងឆ្នាំ ១៩៩០ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ និន្នាការនេះក៏ត្រូវបានពង្រឹងផងដែរ ដោយការធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងទីផ្សារតំបន់ និងពិភពលោក បន្ទាប់ពីកម្ពុជាបានក្លាយជាប្រទេសសមាជិកអាស៊ានក្នុងឆ្នាំនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច និងសមាហរណកម្មសេដ្ឋកិច្ចបានផ្តល់ បរិយាកាសល្អសម្រាប់ការវិនិយោគនៅកម្ពុជាក៏ដោយ ប្រសិនបើគ្មានកិច្ចខិតខំប្រឹងប្រែងគោលនយោបាយសកម្មដោយរដ្ឋាភិបាលចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៩០នោះការកើនឡើងយ៉ាងឆាប់រហ័សនៃលំហូរការវិនិយោគពីបរទេសប្រហែលជាមិនមានទេ[30]។ គម្រោងវិនិយោគអាចបង្កើតលក្ខខណ្ឌអំណោយផលទាក់ទងនឹងពន្ធលើប្រាក់ចំណេញ សម្រាប់រយៈពេលដែលបានកំណត់ ប្រសិនបើអាចទទួលបានស្ថានភាពគម្រោង វិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) ពីរដ្ឋាភិបាល។ គោលនយោបាយនេះបានរួមចំណែកដល់ការកើនឡើងយ៉ាងឆាប់រហ័សនៃការវិនិយោគក្នុងស្រុក និងការវិនិយោគផ្ទាល់ពីបរទេស។ បណ្តាប្រទេសនៅអាស៊ីដូចជា ចិន កូរ៉េខាងត្បូង ម៉ាឡេស៊ី ជប៉ុន និងថៃ គឺជាប្រទេសប្រភពសំខាន់នៃការវិនិយោគផ្ទាល់ពីបរទេសមកកម្ពុជា យោងតាមក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)។ មិនតែប៉ុណ្ណោះវិស័យកាត់ដេរនិងស្បែកជើង ថាមពលនិងសំណង់បានទាក់ទាញលំហូរចូលការវិនិយោគផ្ទាល់ពីបរទេសជាចម្បង។

## ២.៥. គុណសម្បត្តិ និងគុណវិបត្តិរបស់ដុល្លារូបនីយកម្ម[31]

ដុល្លារូបនីយកម្ម (Dollarization) គឺជាការចាប់យករូបិយប័ណ្ណរបស់បរទេសណាមួយសម្រាប់ធ្វើការទូទាត់ស្របច្បាប់នៅក្នុងប្រតិបត្តិការរូបិយវត្ថុ។ ដុល្លារូបនីយកម្មក្រៅផ្លូវការមានន័យថា ប្រជាពលរដ្ឋចូលចិត្តរូបិយប័ណ្ណបរទេសសម្រាប់ប្រតិបត្តិការមួយចំនួនទោះបីជាវាមិនអាចជាការទូទាត់មានលក្ខណៈផ្លូវការក៏ដោយ។ ដុល្លារូបនីយកម្មជាផ្លូវការមានន័យថា រូបិយប័ណ្ណបរទេសក្លាយជាការទូទាត់ដ៏ពេញចិត្តនៅក្នុងប្រទេសខណៈរូបិយប័ណ្ណក្នុងស្រុកក៏អាចទទួលយកផងដែរ។

---

[30] It is also important to note that the relatively low labor wage in Cambodia is also a factor attracting FDI.

[31] Khemsaritheducation, “គុណសម្បត្តិ និងគុណវិបត្តិរបស់ដុល្លារូបនីយកម្ម”, ២១ ឧសភា ២០១៨, https://khemsaritheducation.wordpress.com/

មូលហេតុចម្បងសម្រាប់ដុល្លារូបនីយកម្ម គឺដើម្បីជំនួសរូបិយប័ណ្ណដែលមានស្ថេរភាពសម្រាប់រូបិយប័ណ្ណមិនមានស្ថេរភាពមួយ។ ជាទូទៅប្រាក់ដុល្លារូបនីយកម្មពាក់ព័ន្ធនឹងប្រាក់ដុល្លារសហរដ្ឋអាមេរិក ទោះបីជាវាអាចត្រូវបានផ្អែកលើរូបិយប័ណ្ណផ្សេងទៀតដូចជាប្រាក់អឺរ៉ូជាដើម។

## ២.៥.១. គុណសម្បត្តិរបស់ដុល្លារូបនីយកម្ម

គុណប្រយោជន៍ គឺនៅត្រង់ថានៅក្នុងពេលដែលសាធារណជនមិនមានទំនុកចិត្តលើលុយរៀល ការអនុញ្ញាតឱ្យចាយលុយដុល្លារអាចបញ្ចៀស កុំឱ្យកម្ពុជាត្រូវប្រឈមមុខនឹងចលនាហូរចេញមូលធនទៅក្រៅប្រទេស។ ដោយសារតែមិនមានទំនុកចិត្តលើលុយរៀល អ្នកមានលុយមិនចង់រក្សាទុកលុយរៀលច្រើន ហើយនាំគ្នាស្វះស្វែងរកកន្លែងទុកលុយជាដុល្លារ ឬលុយបរទេសផ្សេងទៀត ដែលគេគិតថាមានហានិភ័យតិចជាង។

ប្រសិនបើនៅកម្ពុជា ដុល្លារមិនត្រូវបានអនុញ្ញាតឱ្យធ្វើចរាចរយ៉ាងទូលំទូលាយដូចសព្វថ្ងៃនេះទេ ដើម្បីអាចទុកលុយជាដុល្លារ គេប្រាកដជាត្រូវយកលុយទៅទុកនៅក្នុងធនាគានៅឯក្រៅប្រទេស ហើយមូលធនដែលជាកត្តាសំខាន់សម្រាប់កំណើនសេដ្ឋកិច្ចជាតិ នឹងត្រូវហូរចេញទៅក្រៅប្រទេស ឬក្នុងករណីខ្លះទៀត អ្នកមានលុយ ដែលមិនចង់ទុកជាលុយរៀល ហើយក៏មិនអាចទុកជាដុល្លារនៅក្នុងប្រទេសបាន អាចនាំគ្នាយកលុយទៅទិញមាសទុកជំនួស វិញ។ ការទុកលុយជាមាសនេះ ក៏មិនខុសពីការយកលុយទៅទុកនៅឯធនាគារបរទេសដែរ គឺវានាំឱ្យកម្ពុជាត្រូវបាត់បង់មូលធនសម្រាប់ជំរុញកំណើនសេដ្ឋកិច្ច។

គុណប្រយោជន៍មួយទៀតនៃការចាយលុយដុល្លារ គឺវាជួយសម្រួលដល់កម្ពុជាក្នុងការធ្វើសមាហរណកម្មក្នុងពាណិជ្ជកម្មអន្តរជាតិ។ ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណដ៏មានស្ថិរភាពបានជួយកម្ពុជាឱ្យមានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងបង្កើតបរិយាកាស ដែលមានអំណោយផល សម្រាប់ការធ្វើជំនួញ។ ការចាយលុយដុល្លារធ្វើឱ្យអ្នកជំនួញអាចកាត់បន្ថយការចំណាយទៅលើការប្តូរប្រាក់រវាងលុយរៀលនឹងលុយដុល្លារ ហើយហានិភ័យនៃអត្រាប្តូរប្រាក់ក៏ត្រូវកាត់បន្ថយច្រើនផងដែរ។ ទាំងនេះគឺជាកត្តាសំខាន់មួយ ដែលជំរុញឱ្យមានវិនិយោគបរទេសនៅក្នុងប្រទេសកម្ពុជា ជាពិសេសនៅក្នុងវិស័យកាត់ដេរ។

## ២.៥.២. គុណវិបត្តិរបស់ដុល្លារូបនីយកម្ម

ទន្ទឹមនឹងគុណប្រយោជន៍អស់ទាំងនេះ ការចាយលុយដុល្លារក៏មានគុណវិបត្តិច្រើនផងដែរ។ គុណវិបត្តិធំជាងគេ គឺកម្ពុជាត្រូវបាត់បង់អាវុធដ៏សំខាន់មួយនៅក្នុងនយោបាយម៉ាក្រូសេដ្ឋកិច្ច គឺនយោបាយរូបិយវត្ថុ។ ការចាយលុយដុល្លារអាមេរិកយ៉ាងទូលំទូលាយដូចជាពេលបច្ចុប្បន្ននេះ មានន័យថាទោះចង់មិនចង់មួយផ្នែកធំនៃនយោបាយរូបិយវត្ថុរបស់កម្ពុជា ត្រូវបានផ្ទេរទៅឱ្យធនាគារកណ្តាលអាមេរិកជាអ្នកចាត់ចែងជំនួសធនាគារជាតិកម្ពុជាវិញ។

គេអាចនិយាយថា អាមេរិកជាមហាអំណាចសេដ្ឋកិច្ចពិភពលោក ហើយធនាគារកណ្តាលអាមេរិកជាស្ថាប័ន ដែលមានសមត្ថភាពខ្ពស់ និងដែលគួរឱ្យគេទុកចិត្ត។ ដូច្នេះ បើឱ្យអាមេរិកជាអ្នកចាត់ចែងនយោបាយរូបិយវត្ថុជំនួយធនាគារជាតិកម្ពុជា វាក៏គួរជារឿងល្អដែរ។ ក៏ប៉ុន្តែគេមិនគួរភ្លេចទេថាប្រទេសនីមួយៗមានលក្ខណៈពិសេសរៀងៗខ្លួន និងមានស្ថានភាពសេដ្ឋកិច្ចខុសគ្នា ហើយពេលខ្លះចាំបាច់ត្រូវមាននយោបាយសេដ្ឋកិច្ចខុសគ្នា ដើម្បីឆ្លើយតបទៅនឹងតម្រូវការសេដ្ឋកិច្ចរៀងៗខ្លួន។

ម្យ៉ាងទៀត រូបិយប័ណ្ណជាតិ គឺជានិមិត្តរូបដ៏សំខាន់មួយនៃអធិបតេយ្យជាតិ។ ដូច្នេះការចាយលុយរៀលដែលជារូបិយប័ណ្ណជាតិ និងការគ្រប់គ្រងនយោបាយរូបិយវត្ថុយ៉ាងពេញលេញដោយខ្លួនឯង វាមិនត្រឹមតែផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ចជាតិប៉ុណ្ណោះទេ តែវាក៏ជាមោទនភាពរបស់ជាតិខ្មែរទាំងមូលផងដែរ។ ក៏ប៉ុន្តែដើម្បីឱ្យលុយរៀលត្រូវបានគេប្រើប្រាស់ច្រើន និងជាមោទនភាពរបស់ជាតិខ្មែរបាន រដ្ឋាភិបាលកម្ពុជាចាំបាច់ត្រូវតែដាក់ចេញនូវនយោបាយ ដើម្បីស្តារទំនុកចិត្តលើលុយរៀលឡើងវិញ។

# ជំពូកទី៣

# ស្ថានភាពគោលនយោបាយ

# រូបិយប័ណ្ណនៅប្រទេសកម្ពុជា

# ជំពូកទី៣

# ស្ថានភាពគោលនយោបាយរូបិយប័ណ្ណនៅប្រទេសកម្ពុជា

## ៣.១. គោលនយោបាយរូបិយវត្ថុ[32]

គោលនយោបាយរូបិយវត្ថុ (Monetary Policy) គឺជាសំណុំនៃឧបករណ៍ដែលប្រើប្រាស់ដោយធនាគារកណ្តាលរបស់ប្រទេសមួយ ដើម្បីគ្រប់គ្រងការផ្គត់ផ្គង់ប្រាក់ទាំងមូល និងលើកកម្ពស់កំណើនសេដ្ឋកិច្ច តាមរយៈការប្រើប្រាស់យុទ្ធសាស្ត្រដូចជា កែសម្រួលអត្រាការប្រាក់ និងការផ្លាស់ប្តូរតម្រូវការទុនបម្រុងធនាគារជាដើម។

គោលនយោបាយរូបិយវត្ថុគឺជាការគ្រប់គ្រងបរិមាណសាច់ប្រាក់ដែលមាននៅក្នុងសេដ្ឋកិច្ចនិងបណ្តាញដែលប្រាក់ថ្មីត្រូវបានផ្គត់ផ្គង់។ ស្ថិតិក្នុងវិស័យសេដ្ឋកិច្ចជាច្រើនដូចជា ផលិតផលក្នុងស្រុកសរុបអតិផរណា កំណើនឧស្សាហកម្ម និងវិស័យផ្សេងទៀតសុទ្ធតែរងឥទ្ធិពលពីយុទ្ធសាស្ត្រគោលនយោបាយរូបិយវត្ថុ។

### ៣.១.១. គោលដៅនៃគោលនយោបាយរូបិយវត្ថុ

គោលនយោបាយរូបិយវត្ថុត្រូវបានប្រើដើម្បីទប់ស្កាត់អតិផរណា និងកាត់បន្ថយកម្រិតនៃប្រាក់ដែលចរាចរនៅក្នុងសេដ្ឋកិច្ច។ គោលនយោបាយរូបិយវត្ថុដែលធូររលុង ជំរុញឱ្យមានសម្ពាធអតិផរណាកើនឡើង និងបង្កើនបរិមាណប្រាក់ក្នុងចរាចរ។ យ៉ាងណាមិញ គោលនយោបាយរូបិយវត្ថុធូររលុងអាចកាត់បន្ថយភាពអត្រាអត់ការងារធ្វើ ដោយសារការផ្គត់ផ្គង់ប្រាក់កាន់តែខ្ពស់ និងអត្រាការប្រាក់ដ៏ទាក់ទាញជំរុញសកម្មភាពអាជីវកម្ម និងការពង្រីកទីផ្សារការងារ។

លើសពីនេះ អត្រាប្តូរប្រាក់រវាងរូបិយប័ណ្ណក្នុងស្រុក និងរូបិយប័ណ្ណបរទេសអាចរងផលប៉ះពាល់ដោយសារគោលនយោបាយរូបិយវត្ថុ។ កាលណាការផ្គត់ផ្គង់ប្រាក់រូបិយប័ណ្ណក្នុងស្រុកច្រើនលើសលប់ នឹងធ្វើឱ្យរូបិយប័ណ្ណក្នុងស្រុបមានតម្លៃថោកនៅពេលប្តូរជាមួយរូបិយប័ណ្ណបរទេស។

[32] ធន់ សេងហុង, “តើគោលនយោបាយរូបិយវត្ថុជាអ្វី?”, ១២ តុលា ២០២៣,
https://thmeythmey.com/?page=detail&id=130758

### ៣.១.២. ប្រភេទនៃគោលនយោបាយរូបិយវត្ថុ

គោលនយោបាយរូបិយវត្ថុចែកចេញជាពីរប្រភេទគឺ៖

- **<u>គោលនយោបាយរូបិយវត្ថុពង្រីក</u>**៖ សំដៅលើការបង្កើនបរិមាណផ្គត់ផ្គង់រូបិយវត្ថុសរុប។ វាបានប្រើដោយធនាគារកណ្ដាលដើម្បីចៀសវាងវិបត្តិសេដ្ឋកិច្ច និងគ្រប់គ្រងភាពគ្មានការងារធ្វើ។ ធនាគារផ្ដល់នូវប្រាក់កម្ចីកាន់តែមានតម្លៃសមរម្យ និងកំណត់អត្រាការប្រាក់ទាប អាជីវកម្មអាចខ្ចីប្រាក់បន្ថែមបានច្រើនដើម្បីចំណាយលើបុគ្គលិក ពង្រីកការចំណាយ និងទិញសម្ភារៈផ្សេងៗ។ ម៉្យាងវិញទៀត ប្រជាជនអាចទិញរថយន្តថ្មី គ្រឿងសម្ភារៈប្រើប្រាស់ និងគេហដ្ឋាននឹងកើន ពេលនោះនឹងជំរុញសេដ្ឋកិច្ច និងតម្រូវការកើនឡើង។

គោលនយោបាយរូបិយវត្ថុពង្រីក មានគោលបំណងបង្កើនការផ្គត់ផ្គង់ រូបិយវត្ថុ និងទិញមូលបត្របំណុលរបស់រដ្ឋាភិបាល ដើម្បីកាត់បន្ថយអត្រាការប្រាក់ និងកាត់បន្ថយទុនបម្រុងកាតព្វកិច្ច។ វាជំរុញកំណើនអាជីវកម្ម និងកាត់បន្ថយអត្រាអនិកម្មភាព។ គោលបំណងនៃគោលនយោបាយពង្រីក ដើម្បីជំរុញកំណើនសេដ្ឋកិច្ច ហើយពេលខ្លះវាអាចបណ្ដាលឱ្យមានអតិផរណាខ្ពស់។

- **<u>គោលនយោបាយរូបិយវត្ថុបង្រួម</u>**៖ សំដៅលើការបន្ថយបរិមាណការផ្គត់ផ្គង់រូបិយវត្ថុ។ វាបានប្រើដោយធនាគារកណ្ដាលដើម្បីគ្រប់គ្រងអតិផរណា។ គោលនយោបាយនេះកំណត់បរិមាណរូបិយវត្ថុដែលអាចខ្ចីដោយធនាគារដើម្បីគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុ។ ជាលទ្ធផលធនាគារផ្ដល់នូវប្រាក់កម្ចីកាន់តែថ្លៃជាងមុន ដោយគិតអត្រាការប្រាក់កាន់តែខ្ពស់ជាង។

គោលនយោបាយរូបិយវត្ថុបង្រួម មានគោលបំណងកាត់បន្ថយការផ្គត់ផ្គង់ រូបិយវត្ថុនៅក្នុងសេដ្ឋកិច្ច។ នេះអាចត្រូវបានធ្វើដោយការបង្កើនអត្រាការប្រាក់លើការលក់មូលបត្របំណុលរដ្ឋាភិបាល ឬបង្កើនទុនបម្រុងកាតព្វកិច្ច។ គោលនយោបាយនេះប្រើនៅពេលរដ្ឋាភិបាលចង់គ្រប់គ្រងកម្រិតអតិផរណា។

### ៣.២. គោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិកម្ពុជា[33]

បេសកកម្មចម្បងរបស់ធនាគារជាតិនៃកម្ពុជា គឺកំណត់និងដឹកនាំគោលនយោបាយរូបិយវត្ថុសំដៅរក្សាស្ថិរភាពថ្លៃដើម្បីរួមចំណែកជំរុញការអភិវឌ្ឍសេដ្ឋកិច្ច ក្នុងក្របខ័ណ្ឌនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃ

[33] ធនាគារជាតិនៃកម្ពុជា, “ទិដ្ឋភាពទូទៅនៃគោលនយោបាយរូបិយវត្ថុ”, បានចូលទាញនៅថ្ងៃទី ២០ កក្កដា ២០២៤, https://www.nbc.gov.kh/monetary_policy/overview.php

ព្រះរាជាណាចក្រកម្ពុជា។ តាមរយៈការអនុវត្តគោលនយោបាយរូបិយវត្ថុ ប្រកបដោយភាពប្រុងប្រយ័ត្ន អតិផរណាត្រូវបានគ្រប់គ្រងឱ្យស្ថិតក្នុងកម្រិតទាប ក្នុងអត្រាមធ្យមប្រចាំឆ្នាំតិចជាង ៥% ដែលសមស្របសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍។ ទោះជាយ៉ាងនេះក្តី ក្នុងបរិការណ៍សេដ្ឋកិច្ចដែលមានកម្រិតដុល្លារូបនីយកម្មខ្ពស់ ប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយរូបិយវត្ថុនៅមានកម្រិតនៅឡើយ ស្របពេលដែលធនាគារជាតិនៃកម្ពុជាពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការដើរតួជាអ្នកឱ្យខ្ចីចុងក្រោយ។

បច្ចុប្បន្នឧបករណ៍គោលនយោបាយរូបិយវត្ថុដែលត្រូវបានប្រើប្រាស់ដើម្បីរក្សាស្ថិរភាពថ្លៃ គឺការដាក់អត្រាប្រាក់បម្រុងកាតព្វកិច្ច និងការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់។ ជាមួយគ្នានេះធនាគារជាតិនៃកម្ពុជាបានកំពុងអភិវឌ្ឍន៍ ឧបករណ៍គោលនយោបាយរូបិយវត្ថុបន្ថែមដើម្បីពង្រឹងប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុតាមរយៈការចេញផ្សាយមូលបត្រអាចជួញដូរបាន ការអភិវឌ្ឍទីផ្សារអន្តរធនាគារនិងទីផ្សាររូបិយវត្ថុ និងការពង្រឹងការប្រើប្រាស់ប្រាក់រៀល។

## ៣.៣. សារៈប្រយោជន៍នៃការប្រើប្រាស់ប្រាក់រៀល[34]

រូបិយប័ណ្ណប្រាក់រៀលកម្ពុជា ក្រៅពីជានិមិត្តសញ្ញា និងអត្តសញ្ញាណពិសេសដល់ជាតិក៏ជាឧបករណ៍ប្រើប្រាស់ក្នុងការដោះដូរទំនិញ និងសេវាក្នុងទីផ្សារផងដែរ យ៉ាងណាមិញប្រទេសកម្ពុជាបានឆ្លងកាត់សង្គ្រាមជាច្រើនលើកច្រើនសារធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាត្រលប់ទៅរកចំនុចសូន្យ ការបាត់បង់ជំនឿទៅលើរូបិយប័ណ្ណជាតិក៏កើតមានឡើង សកម្មភាពសេដ្ឋកិច្ចសំខាន់ៗត្រូវបានជំនួសដោយរូបិយវត្ថុបរទេស។ បច្ចុប្បន្នធនាគារជាតិព្យាយាមកាត់បន្ថយឥទ្ធិពលលុយដុល្លារក្នុងពេលមានវិបត្តិសកលដោយសារកូវីដ១៩ ជាលទ្ធផលមានការប្រើប្រាស់លុយរៀលច្រើនជាងមុនក្នុងទីផ្សារ ដូច្នេះយើងគួរតែចូលរួមកាត់បន្ថយការប្រើប្រាស់រូបិយវត្ថុបរទេស និងងាកមកប្រើប្រាស់រូបិយប័ណ្ណជាតិ លុយរៀលខ្មែរ ព្រោះនឹងផ្តល់អត្ថប្រយោជន៍ដូចជា៖

### ៣.៣.១. លើកតម្កើងអត្តសញ្ញាណជាតិ

គ្រប់បណ្តាប្រទេសនៅលើពិភពលោក សុទ្ធតែមានរូបិយវត្ថុរៀងខ្លួន។ ដូចគ្នានឹងប្រទេសកម្ពុជាមានរូបិយវត្ថុរបស់ខ្លួនដែរ គឺលុយរៀល។ ដូចនេះប្រជាពលរដ្ឋកម្ពុជាគួររួមគ្នា ប្រើប្រាស់លុយរៀលដែលជាអត្តសញ្ញាណជាតិចូលរួមលើកតម្លៃលុយរៀល ធ្វើឱ្យលុយរៀលមានតម្លៃមានហាងឆេង ព្រោះកាលណាពលរដ្ឋប្រើប្រាស់រូបិយប័ណ្ណមានន័យថា កំពុងតែធ្វើឱ្យលុយរៀលចាប់ផ្តើមធ្លាក់តម្លៃបន្តិចម្តងៗដូច្នោះដែរ។

[34] ធនាគារជាតិនៃកម្ពុជា, "សារៈប្រយោជន៍នៃការប្រើប្រាស់ប្រាក់រៀល", ៤ ឧសភា ២០២២, https://www.nbc.gov.kh

### ៣.៣.២. រក្សាស្ថិរភាពថ្លៃ

ត្រង់ចំណុចនេះមានន័យថា នៅពេលប្រជាពលរដ្ឋរួមគ្នាកាត់បន្ថយប្រើប្រាស់រូបិយប័ណ្ណផ្សេង ដូចជាលុយដុល្លារជាដើម គឺកំពុងចូលរួមកាត់បន្ថយអតិផរណា (លុយចុះថោក ទំនិញឡើងថ្លៃ)។ ហេតុផលនេះដោយសារ ធនាគារជាតិអាចធ្វើការផ្គត់ផ្គង់សាច់ប្រាក់នៅក្នុងទីផ្សារបានល្អ នៅពេលអ្នកចាយលុយរៀលកាន់តែច្រើន ព្រោះជាធម្មតាធនាគារមិនអាចគ្រប់គ្រងសាច់ប្រាក់ ឬបោះពុម្ពលុយឱ្យសមស្របនឹងទីផ្សារនោះឡើយប្រសិនបើមានតែអ្នកប្រើប្រាស់លុយដុល្លារ។ ដូច្នេះហើយការចាយលុយរៀលពិតជាសំខាន់ក្នុងការរក្សាតម្លៃឱ្យមានស្ថិរភាព ត្រូវដឹងថាចាយលុយផ្សេងកាន់តែច្រើនលុយរៀលកាន់តែធ្លាក់តម្លៃ។

### ៣.៣.៣. កាត់បន្ថយចំណាយប្រតិបត្តិការ

ចំណុចនេះជាទូទៅប្រជាពលរដ្ឋភាគច្រើន មិនបានគិតដល់នោះឡើយ។ កាត់បន្ថយចំណាយប្រតិបត្តិការនៅទីនេះចង់សំដៅថា នៅពេលដែលប្រើប្រាស់លុយរៀល គឺមិនចាំបាច់យកលុយរៀលទៅដូរយកលុយដុល្លារនាំឱ្យខាតអត្រាប្តូរប្រាក់នោះឡើយ។ មួយវិញទៀតការប្រើប្រាស់រូបិយវត្ថុតែមួយ ចំពោះការទូទាត់គ្រប់ប្រតិបត្តិការនៅក្នុងសេដ្ឋកិច្ចជាតិ នឹងជួយកាត់បន្ថយចំណាយជាច្រើនសម្រាប់អ្នកលក់ និងអ្នកទិញ។ លើសពីនេះ ការប្រើប្រាស់នេះនឹងអាចជួយបង្កើនប្រតិបត្តិការសេដ្ឋកិច្ចកាន់តែច្រើន មានភាពងាយស្រួល ឆាប់រហ័ស និងមានប្រសិទ្ធភាព នៅពេលភាគីទាំងពីរមិនត្រូវចាំបាច់ខ្វល់ពីគម្លាតអត្រាប្តូរប្រាក់ទេ។

### ៣.៣.៤. ជំរុញពាណិជ្ជកម្ម

ប្រជាពលរដ្ឋមួយចំនួនច្រើនយល់ថា ប្រើប្រាស់រូបិយប័ណ្ណបរទេស ងាយស្រួលក្នុងការធ្វើពាណិជ្ជកម្ម ប៉ុន្តែមិនដូច្នោះឡើយ។ សេដ្ឋកិច្ចកម្ពុជាពឹងផ្អែកមួយភាគធំលើការនាំចេញ និងទេសចរណ៍ដើម្បីជំរុញកំណើនសេដ្ឋកិច្ច។ ដូចនេះប្រសិនបើកម្ពុជាប្រើប្រាស់តែលុយរៀល ធនាគារកណ្តាលអាចជំរុញការនាំចេញដោយធ្វើឱ្យភាពប្រកួតប្រជែងថ្លៃកើនឡើង តាមរយៈការបន្ថយតម្លៃរូបិយវត្ថុ។ ការបន្ថយតម្លៃរូបិយវត្ថុនឹងធ្វើឱ្យការនាំចេញកើនឡើង។

### ៣.៣.៥. ជំរុញការវិនិយោគ

លុយដុល្លារអាមេរិកមានទៅដល់ ៩០% ក្នុងវិស័យហិរញ្ញវត្ថុកម្ពុជា ប៉ុន្តែធនាគារជាតិអាចផ្តល់តែកម្ចីជាលុយរៀលប៉ុណ្ណោះដល់គ្រឹះស្ថានធនាគារ។ មានន័យថា អត្រាការប្រាក់គោលដែលធនាគារជាតិនៃកម្ពុជាបានកំណត់ នឹងមិនមានឥទ្ធិពលលើថ្លៃដើមនៃមូលនិធិវិនិយោគរបស់គ្រឹះស្ថានធនាគារនោះទេ។ ចំណុចនេះជាគុណវិបត្តិដ៏ធំមួយរបស់ប្រជាជនកម្ពុជា និងអ្នកវិនិយោគដែលកំពុងប្រឈមនឹងចំណាយថ្លៃដើមវិនិយោគខ្ពស់ដោយសារធនាគារជាតិមិនអាចមានឥទ្ធិពលលើអត្រាការប្រាក់កម្ចី របស់គ្រឹះស្ថានធនាគារនោះទេ។

### ៣.៣.៦. លើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធ និងសុខុមាលភាពសង្គម

ប្រសិនបើប្រជាពលរដ្ឋឈប់ប្រើប្រាស់លុយដុល្លារ ឬរូបិយប័ណ្ណផ្សេង គឺជាការរួមចំណែកយ៉ាងសំខាន់ក្នុងការធ្វើឱ្យថវិការដ្ឋមានភាពប្រសើរឡើង និងកាត់បន្ថយការដាក់កំហិតលើគោលនយោបាយសារពើពន្ធ។ ប្រសិនបើនៅលើទីផ្សារមានប្រាក់រៀលកាន់តែច្រើន រាជរដ្ឋាភិបាលអាចពិចារណាចេញផ្សាយមូលបត្រចារឹកជាប្រាក់រៀល ដើម្បីគ្រប់គ្រងថវិកា ក៏ដូចជាផ្តល់ហិរញ្ញប្បទាន លើគម្រោងអភិវឌ្ឍន៍នានា។ ដូចនេះលទ្ធភាពក្នុងការគ្រប់គ្រងហិរញ្ញប្បទានក្នុងស្រុក នឹងអាចជួយឱ្យកម្ពុជាកាត់បន្ថយការពឹងផ្អែកលើបំណុលបរទេស។

### ៣.៣.៧. ទទួលបានចំណូលពីការបោះពុម្ពក្រដាសប្រាក់

កំណើនតម្រូវការប្រាក់រៀលកាន់តែច្រើន នឹងធ្វើឱ្យធនាគារជាតិនៃកម្ពុជាអាចបោះផ្សាយក្រដាសប្រាក់រៀលកាន់តែច្រើន។ នៅពេលដែលការបោះពុម្ពលុយរៀលកាន់តែច្រើន នោះកម្ពុជាទទួលបានចំណូលពីការបោះពុម្ពលុយកាន់តែច្រើនដែរ។ ដូចនេះរាជរដ្ឋាភិបាល នឹងទទួលបានមូលនិធិក្នុងនាមជាអ្នកខ្ចីពីធនាគារកណ្តាលដោយពុំមានការប្រាក់ ដើម្បីយកទៅធ្វើការវិនិយោគទៅក្នុងសេដ្ឋកិច្ច ការអភិវឌ្ឍផ្សេងៗ។

### ៣.៣.៨. បង្ការការក្លែងក្រដាសប្រាក់

នេះជាចំណុចសំខាន់បំផុតសម្រាប់ប្រជាពលរដ្ឋកម្ពុជាជៀសផុតពីការក្លែងក្រដាសប្រាក់។ ការប្រើប្រាស់ រូបិយវត្ថុជាតិដែលប្រជាជនស្គាល់ច្បាស់នឹងជួយកាត់បន្ថយនូវការក្លែងក្រដាសប្រាក់ និងជួយបង្ការការក្លែងក្រដាសប្រាក់លើរូបិយប័ណ្ណបរទេសដោយសាររូបិយប័ណ្ណទាំងនេះនឹងហូរចូលក្នុងសេដ្ឋកិច្ចតាមរយៈប្រព័ន្ធធនាគារ។

## ៣.៤. ការលើកកម្ពស់ប្រាក់រៀលក្នុងគោលនយោបាយរបស់ធនាគារជាតិនៃកម្ពុជា[35]

### ៣.៤.១. ការលើកកម្ពស់ប្រាក់រៀលក្នុងទសវត្សរ៍ឆ្នាំ ១៩៩០

ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ កិច្ចខិតខំប្រឹងប្រែងបានបន្តលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលកម្ពុជា (KHR) បើទោះបីជាកម្ពុជាមានរូបិយប័ណ្ណនីយកម្មជាបន្តបន្ទាប់ ចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៩៩០ ក៏ដោយ។ ប្រាក់ដុល្លារអាមេរិកបានជំនួសប្រាក់រៀលភាគច្រើនបានក្លាយជាមុខងាររក្សាតម្លៃ ហើយត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយក្នុងប្រតិបត្តិការប្រចាំថ្ងៃ ក៏ដូចជាសម្រាប់សកម្មភាពនាំចេញ និងនាំចូល។

នៅខែមីនា ឆ្នាំ ១៩៩៥ ធនាគារជាតិនៃកម្ពុជាបានដាក់បង្ហាញក្រដាសប្រាក់រៀលប្រភេទធំ ដែលមានតម្លៃរហូតដល់ ១០ ម៉ឺនរៀល (ប្រហែល ២៥ ដុល្លារអាមេរិក)។ នៅពេលនោះ អតិផរណាមាន ២.៨% ហើយ

[35] Daiju Aiba and Sovanney Chey, “Its Policy Implications for LDCs’ Financial Development.", accessed 01 August 2024 https://www.jica.go.jp/english/jica_ri/news/topics/2023/1520896_24294.html

អត្រាប្តូរប្រាក់បានឡើងថ្លៃដល់ ២,៤៨៣ រៀលក្នុងមួយដុល្លារអាមេរិក។ ការចេញនេះមានគោលបំណងលើកទឹកចិត្តឱ្យប្រើប្រាក់រៀល និងបញ្ឈប់ក្រដាសប្រាក់ដុល្លារអាមេរិកតូចៗ ដូចជាក្រដាសប្រាក់ ២០ ដុល្លារអាមេរិក។ ទោះជាយ៉ាងណាក៏ដោយ ក្រដាសប្រាក់រៀលធំទាំងនេះមិនត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយទេ ដោយសារតែមានកំណត់ក្នុងការប្រគល់វាមក ធនាគារជាតិនៃកម្ពុជាដោយបន្សល់ទុកក្រដាសប្រាក់ចាស់ៗនៅតែមានចរាចរ។

ចាប់តាំងពីឆ្នាំ ១៩៩៨ មកធនាគារជាតិនៃកម្ពុជាបានផ្តោតលើស្ថិរភាពអត្រាប្តូរប្រាក់ ដើម្បីបង្កើនទំនុកចិត្តសាធារណៈលើប្រាក់រៀលកម្ពុជា និងលើកទឹកចិត្តដល់ការប្រើប្រាស់របស់ខ្លួនសម្រាប់ការសន្សំ និងការទូទាត់ នៅពេលដែលទំនុកចិត្តកើនឡើង ការប្រើប្រាស់ប្រាក់រៀលកើនឡើង។ ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ ការប្រែប្រួលនៃអត្រាប្តូរប្រាក់នៅតែទាបជាង ២% ជារៀងរាល់ឆ្នាំដែលជួយរក្សាស្ថិរភាពតម្លៃនៅក្នុងសេដ្ឋកិច្ចកម្ពុជា។ ធនាគារជាតិនៃកម្ពុជា បានធ្វើឱ្យតម្លៃប្រាក់រៀលមានស្ថិរភាព តាមរយៈអន្តរាគមន៍ប្តូរប្រាក់បរទេស លក់ប្រាក់ដុល្លារអាមេរិក និងទិញប្រាក់រៀលនៅពេលប្រាក់រៀលធ្លាក់ចុះ ហើយធ្វើការផ្លាស់ប្តូរនៅពេលប្រាក់រៀលឡើងថ្លៃ។

### ៣.៤.២. ការលើកកម្ពស់ប្រាក់រៀលក្នុងទសវត្សរ៍ឆ្នាំ ២០០០

ការលើកកម្ពស់ប្រាក់រៀលកម្ពុជា គឺជាផ្នែកមួយដ៏សំខាន់នៃគោលនយោបាយជាតិ ដែលមានបែងចែកនៅក្នុងផែនការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ២០០១-២០២១ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០០៦-២០១៥ និង ២០១៦-២០២៥។ ធនាគារជាតិនៃកម្ពុជាបានធ្វើការជាមួយភ្នាក់ងារផ្សេងៗទៀត និងសាធារណជន ដើម្បីគាំទ្រដល់គោលដៅនេះ។ នៅក្នុងខែមិថុនា ឆ្នាំ ២០០៨ ធនាគារជាតិនៃកម្ពុជាបានកំណត់ភាពខុសគ្នានៃទុនបម្រុងកាតព្វកិច្ចដោយរក្សាអត្រាប្រាក់រៀលនៅកម្រិត ៨% និងបង្កើនដល់ ១៦% សម្រាប់រូបិយប័ណ្ណបរទេស។ គោលបំណងនេះ ដើម្បីបង្កើនការចំណាយលើការប្រើប្រាស់រូបិយប័ណ្ណបរទេស និងលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល។ ក្នុងអំឡុងមានវិបត្តិហិរញ្ញវត្ថុសកល គោលនយោបាយនេះបានជួយពន្យឺតកំណើនឥណទានរូបិយប័ណ្ណបរទេស និងលើកទឹកចិត្តដល់ការប្រើប្រាស់ប្រាក់រៀលដែលឆ្លុះបញ្ចាំងពីយុទ្ធសាស្ត្ររបស់ធនាគារជាតិនៃកម្ពុជា ដើម្បីបង្កើនការប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុក បើទោះបីជាមិនមែនជាអ្នកផ្តល់ប្រាក់កម្ចីចុងក្រោយសម្រាប់រូបិយប័ណ្ណបរទេសក៏ដោយ។

ក្នុងខែមករា ឆ្នាំ២០០៩ ធនាគារជាតិនៃកម្ពុជាបានកាត់បន្ថយទុនបម្រុងកាតព្វកិច្ចសម្រាប់រូបិយប័ណ្ណបរទេសពី ១៦% មកត្រឹម ១២% ខណៈពេលដែលរក្សារូបិយប័ណ្ណក្នុងស្រុកឱ្យនៅត្រឹម ៨% ដើម្បីគ្រប់គ្រងការធ្លាក់ចុះនៃកំណើនឥណទានក្នុងកំឡុងវិបត្តិហិរញ្ញវត្ថុសកល។ ធនាគារជាតិនៃកម្ពុជាក៏បានជំនួសចាស់ ក្រដាស

ប្រាក់ដែលមានក្រដាសប្រាក់ថ្មី ដើម្បីធានាការផ្គត់ផ្គង់គ្រប់គ្រាន់ ធ្វើឱ្យប្រសើរឡើងនូវគុណភាព និងភាពទាក់ទាញនៃប្រាក់រៀល និងបានចេញក្រដាសប្រាក់ថ្មីជាទៀងទាត់ ដើម្បីពង្រីកការប្រើប្រាស់របស់ខ្លួនសាធារណជនបានអនុគ្រោះដល់ការកាន់កាប់ក្រដាសប្រាក់រៀលថ្មីជាមធ្យោបាយទូទាត់ និងរក្សាទុកតម្លៃ។

### ៣.៤.៣. ការលើកកម្ពស់ប្រាក់រៀលចាប់តាំងពីឆ្នាំ ២០១០

ចាប់តាំងពីទសវត្សរ៍ឆ្នាំ ២០១០ មកធនាគារជាតិនៃកម្ពុជាបានលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលកម្ពុជា។ បន្ទាប់ពីវិបត្តិហិរញ្ញវត្ថុសកល ធនាគារជាតិនៃកម្ពុជាបានដំឡើងតម្រូវការបម្រុងរូបិយប័ណ្ណបរទេសដល់ ១២.៥% ក្នុងឆ្នាំ២០១២ ដើម្បីគ្រប់គ្រងកំណើនឥណទានប្រាក់ដុល្លារអាមេរិក។ ក្នុងឆ្នាំ ២០១៣ ធនាគារជាតិនៃកម្ពុជាបានណែនាំមូលបត្រអាចជួញដូរបាន (NCDs) ដើម្បីកែលម្អឧបករណ៍ទីផ្សារ និងធនធានហិរញ្ញវត្ថុ។ នៅខែកញ្ញា ឆ្នាំ ២០១៦ ធនាគារជាតិនៃកម្ពុជាបានចាប់ផ្តើមប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ដើម្បីបង្កើតអត្រាគោល លើកកម្ពស់មូលបត្រជួញដូរជាវត្ថុបញ្ចាំ បង្កើនការប្រើប្រាស់ប្រាក់រៀល គាំទ្រវិស័យកសិកម្ម និងអត្រាការប្រាក់ប្រាក់រៀលទាប។ ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានាបានផ្តល់ប្រាក់រៀលដល់ស្ថាប័ននានាជាថ្នូរនឹងវត្ថុបញ្ចាំជាដុល្លារអាមេរិក ជួយឲ្យពួកគេបំពេញតាមតម្រូវការកម្ចីប្រាក់រៀល និងកាត់បន្ថយការចំណាយលើមូលនិធិ។

នៅក្នុងខែធ្នូ ឆ្នាំ ២០១៦ ធនាគារជាតិនៃកម្ពុជាបានតម្រូវឱ្យធនាគារបែងចែកយ៉ាងហោចណាស់ ១០% នៃប្រាក់កម្ចីជាប្រាក់រៀលកម្ពុជានៅដំណាច់ឆ្នាំ ២០១៩។ បទប្បញ្ញត្តិនេះបានបង្កើនប្រាក់កម្ចីប្រាក់រៀលពី ៤.១% ក្នុងឆ្នាំ ២០១៦ ដល់ ១៣.១% ក្នុងឆ្នាំ ២០២០។ ជាមួយនឹងឥណទានប្រាក់រៀលកើនឡើង ១៤.៣% នៅចុងឆ្នាំ ២០១៩ បន្ទាប់មកបន្ថយមកត្រឹម ២៦% នៅឆ្នាំ ២០២០។

នៅឆ្នាំ ២០១៨ ធនាគារជាតិនៃកម្ពុជាបានអនុញ្ញាតឱ្យចេញមូលបត្របំណុលសាជីវកម្មជាប្រាក់រៀល។ ខណៈពេលដែលក្រុមហ៊ុនមួយចំនួន បានចេញមូលបត្ររូបិយប័ណ្ណបរទេសដើម្បីទាក់ទាញអ្នកវិនិយោគក្នុងសេដ្ឋកិច្ចដុល្លារនេះក៏បានពង្រីកដល់មូលបត្ររបស់រដ្ឋាភិបាល ដោយជំរុញការប្រើប្រាស់ប្រាក់រៀលបន្ថែមទៀតនៅក្នុងទីផ្សារហិរញ្ញវត្ថុ។

ធនាគារជាតិនៃកម្ពុជាបានបង្កើនការប្រើប្រាស់ប្រាក់រៀលសម្រាប់ការទូទាត់ឆ្លងប្រទេស។ នៅក្នុងខែកុម្ភៈ ឆ្នាំ ២០២០ ប្រព័ន្ធទូទាត់តាមកូដ (QR) ត្រូវបានដាក់ឱ្យដំណើរការរវាងប្រទេសកម្ពុជា និងប្រទេសថៃដែលអនុញ្ញាតឱ្យទូទាត់ជាប្រាក់រៀល ឬប្រាក់បាតតាមរយៈធនាគារចល័ត។ គំនិតផ្តួចផ្តើមស្រដៀងគ្នារវាងកម្ពុជា និងម៉ាឡេស៊ី រួមបញ្ចូលវេទិកាឌីជីថលរបស់ធនាគារ Maybank ជាមួយនឹងប្រព័ន្ធទូទាត់បាគងរបស់កម្ពុជា។

គម្រោងបាគង (Bakong) មានគោលបំណងជួយដល់សេដ្ឋកិច្ចដែលគ្មានសាច់ប្រាក់ ហើយត្រូវបានគេជឿថាបានកាត់បន្ថយចរាចរប្រាក់ដុល្លារអាមេរិកនៅលើទីផ្សារ។

កាលពីខែឧសភា ឆ្នាំ ២០២០ ធនាគារជាតិនៃកម្ពុជាបានប្រកាសពីដំណាក់កាលនៃការដកក្រដាសប្រាក់ដុល្លារអាមេរិកខ្នាតតូច (១ ដុល្លារ ២ ដុល្លារ និង ៥ ដុល្លារអាមេរិក) ដើម្បីលើកកម្ពស់ទូទាត់ថ្លៃទំនិញតាមរយៈធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុជាប្រាក់រៀល។

# ជំពូកទី៤

# ការវិភាគទិន្នន័យ និង

# ការបកស្រាយទិន្នន័យ

# ជំពូកទី៤

# ការវិភាគទិន្នន័យ និងការបកស្រាយទិន្នន័យ

## ៤.១. ការប្រើប្រាស់រូបិយប័ណ្ណបរទេសក្នុងប្រតិបត្តិការប្រចាំថ្ងៃ[36]

យោងតាមការស្ទង់មតិរបស់ NBC និង JICA ត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ ២០១៤ និង ២០១៧ ដើម្បីប្រមូលទិន្នន័យស្តីពីការប្រើប្រាស់រូបិយប័ណ្ណបរទេស និងរូបិយវត្ថុជាតិរបស់គ្រួសារកម្ពុជានៅក្នុងខេត្តទាំង ២៥។

ការស្ទង់មតិនេះបានសួរគ្រួសារ ស្តីអំពីសមាមាត្រនៃការប្រើប្រាស់រូបិយប័ណ្ណបរទេសដែលបែងចែកជា ១៤ ប្រភេទនៃការចំណាយ។ តារាងទី២ បង្ហាញពីមធ្យមនៃសមាមាត្រនៃការចំណាយជារូបិយប័ណ្ណបរទេសទៅនឹងការចំណាយសរុប។ វាបានបង្ហាញថាប្រាក់ដុល្លារអាមេរិកត្រូវបានប្រើប្រាស់ជាមធ្យមស្មើរគ្រប់ប្រភេទទំនិញ និងវត្ថុទាំងអស់នៅក្នុងប្រទេសកម្ពុជា។ ជាទូទៅសម្រាប់ទំនិញដែលមានតម្លៃទាប ដូចជាអាហារ និងភេសជ្ជៈ គ្រឿងស្រវឹង និងថ្នាំជក់ វិក្កយបត្រទឹក និងភ្លើង ឬសម្រាប់តម្រូវការសុខភាព រួមទាំងសម្ភារៈអនាម័យ គ្រួសារកម្ពុជាភាគច្រើនប្រើប្រាស់ប្រាក់រៀល។ សម្រាប់ទំនិញ ឬរបស់មានតម្លៃខ្ពស់ដូចជា ការជួលផ្ទះ ការទំនាក់ទំនង និងគ្រឿងសង្ហារិម និងឧបករណ៍ប្រើប្រាស់ ពួកគេមានទំនោរប្រើប្រាស់រូបិយប័ណ្ណបរទេសច្រើនជាងសម្រាប់ការចំណាយ។

**តារាងទី២** ៖ សមាមាត្រជាមធ្យមនៃការចំណាយជារូបិយប័ណ្ណបរទេសទៅនឹងការចំណាយសរុប

*Table 2.1* Ratios of foreign exchange expenditure to total expenditure by item (%)

| | *Expenditure on:* | *KHR* | *USD* | *THB* | *VND* | *Number of HHs that answered* |
|---|---|---|---|---|---|---|
| 1 | Food and beverage | 97.0 | 1.1 | 1.2 | 0.7 | 2259 |
| 1.1 | Rice | 97.0 | 1.3 | 1.5 | 0.2 | 1320 |
| 2 | Alcohol and tobacco | 96.3 | 2.3 | 1.0 | 0.4 | 865 |
| 3 | Housing (rental) | 50.8 | 42.1 | 7.0 | 0.0 | 71 |
| 3.1 | Water and electricity | 93.0 | 0.3 | 6.7 | 0.0 | 2199 |
| 4 | Restaurant and eating outside the house | 95.8 | 2.8 | 1.1 | 0.3 | 1896 |
| 5 | Communication (phone card fees, internet fees, etc.) | 61.5 | 37.4 | 1.0 | 0.0 | 2136 |
| 6 | Personal care | 96.0 | 2.0 | 1.8 | 0.3 | 2024 |
| 7 | Transportation | 94.9 | 3.4 | 1.1 | 0.6 | 2096 |
| 8 | Clothing and footwear | 85.5 | 12.2 | 2.0 | 0.3 | 1869 |
| 9 | Recreation and culture | 81.0 | 16.5 | 1.8 | 0.7 | 613 |
| 10 | Medical care | 90.5 | 6.8 | 2.0 | 0.7 | 2156 |
| 11 | Personal effects | 72.1 | 24.4 | 3.2 | 0.3 | 675 |
| 12 | Education | 89.5 | 9.3 | 0.8 | 0.5 | 1405 |
| 13 | Furniture | 51.7 | 45.8 | 2.4 | 0.0 | 424 |
| 14 | Motorbikes or cars | 20.4 | 76.9 | 2.6 | 0.0 | 284 |
| 15 | Miscellaneous or other expenses | 82.4 | 16.0 | 1.4 | 0.2 | 2247 |

**ប្រភព** ៖ The NBC-JICA survey 2017

[36] Vouthy Khou et al, "Dollarization in households.", accessed 03 August 2024, https://www.jica.go.jp/english/jica_ri/news/topics/2023/1520896_24294.html

នៅក្នុងលក្ខខណ្ឌនៃកម្រិតប្រាក់ចំណូលមានភាពខុសគ្នានៅក្នុងវិសាលភាពនៃការប្រើប្រាស់រូបិយប័ណ្ណបរទេស។ ក្រាហ្វិកទី៤ បង្ហាញពីសមាមាត្រជាមធ្យមនៃការចំណាយជារូបិយប័ណ្ណបរទេស និងប្រាក់រៀលរបស់គ្រួសារតាមតំបន់ និងតាមកម្រិតនៃប្រាក់ចំណូល។ រាជធានីភ្នំពេញបង្ហាញពីសមាមាត្រខ្ពស់បំផុតនៃការប្រើប្រាស់ប្រាក់ដុល្លារអាមេរិក ហើយសមាមាត្រធំបំផុតទីពីរខេត្តសៀមរាប។ នេះក៏ដោយសារតែមានលំហូរចូលមូលធនច្រើននៅទីក្រុងភ្នំពេញ និងសៀមរាប មានភ្ញៀវទេសចរ និងការវិនិយោគផ្ទាល់ពីបរទេសច្រើន។ ដូច្នេះសមាមាត្រនៃប្រាក់ដុល្លារអាមេរិកនៅក្នុងទីក្រុងទាំងពីរនេះគឺខ្ពស់។

កម្រិតនៃប្រាក់ចំណូលក្នុងគ្រួសារកាន់តែខ្ពស់ការប្រើប្រាស់ រូបិយប័ណ្ណបរទេសក៏កាន់តែច្រើន។ នេះអាចឆ្លុះបញ្ចាំងពីការពិតដែលថា គ្រួសារដែលមានប្រាក់ចំណូលខ្ពស់ទំនងជាស្ថិតនៅក្នុងទីក្រុងធំៗដូចជារាជធានីភ្នំពេញ និងខេត្តសៀមរាប។

**ក្រាហ្វិកទី៤** ៖ មធ្យមភាពនៃការចំណាយជារូបិយប័ណ្ណបរទេស និងប្រាក់រៀលរបស់គ្រួសារតាមតំបន់ (រូបភាពទី១) និងតាមកម្រិតនៃប្រាក់ចំណូល (រូបភាពទី២) ទៅនឹងការចំណាយសរុប







**ប្រភព ៖** The NBC-JICA survey 2017

ការស្ទង់មតិរបស់ NBC- JICA ឆ្នាំ ២០១៧ ក៏បានសួរអំពីចំនួនសរុបនៃប្រាក់ចំណូលក្នុងរូបភាពរូបិយប័ណ្ណផ្សេងៗក្នុងរយៈពេល ១២ ខែ។ តាមទិន្នន័យនៃការស្ទង់មតិនេះ យើងឃើញថាសមាមាត្រមធ្យមនៃប្រាក់ចំណូលគ្រួសារគិតជាប្រាក់រៀលគឺ ៧១,៣% បន្ទាប់មកប្រាក់ដុល្លារអាមេរិកមាន ២៣,១% ប្រាក់បាតថៃ (THB) ៥,៣% និងប្រាក់ដុងវៀតណាម (VND) ០,៣% ។ ការស្ទង់មតិបានបង្ហាញថាប្រាក់ចំណូលជាមធ្យមត្រូវបានទទួលជាប្រាក់រៀលសម្រាប់គ្រួសារនីមួយៗ។ នៅក្នុងក្រាហ្វិកទី៥ យើងអង្កេតបន្ថែមទៀតអំពីភាពខុសគ្នានៃរូបិយប័ណ្ណបរទេសនៅក្នុងប្រាក់ចំណូលនៅតាមតំបន់ និងកម្រិតប្រាក់ចំណូល។ ក្រាហ្វិកទី៥ បង្ហាញពីសមាមាត្រជាមធ្យមនៃប្រាក់ចំណូលជារូបិយប័ណ្ណបរទេស និងប្រាក់រៀលចំពោះប្រាក់ចំណូលសរុប។ យើងរកឃើញថាកម្រិតនៃប្រាក់ដុល្លារក្នុងប្រាក់ចំណូលគ្រួសារកើនឡើងជាមួយនឹងកម្រិតនៃប្រាក់ចំណូល និងប្រែប្រួលតាមតំបន់នីមួយៗ។ រាជធានីភ្នំពេញហាក់ដូចជាតំបន់ដែលមានប្រាក់ដុល្លារច្រើនជាងគេ ដោយសមាមាត្រនៃប្រាក់ដុល្លារអាមេរិកមានចំនួន ៤៥.១% បន្ទាប់មកគឺខេត្តសៀមរាប តំបន់ខាងជើង-ខាងលិច និងតំបន់ភាគនិរតី។ យើងគួរបានកត់សម្គាល់ថានៅតំបន់ខាងជើង-ខាងលិច សមាមាត្រខ្ពស់នៃរូបិយប័ណ្ណបរទេសគឺដោយសារតែសមាមាត្រខ្ពស់នៃប្រាក់បាតថៃ ដោយសារតែមានព្រំដែនជាប់បឹងប្រទេសថៃ។ ប្រជាជនកម្ពុជាជាច្រើនអាចទទួលបានប្រាក់ចំណូលជាប្រាក់បាតពីការនាំចេញផលិតផលទៅប្រទេសថៃ។

**ក្រាហ្វិកទី៥ ៖** ភាពខុសគ្នានៃការជ្រើសរើសប្រាក់ចំណូលជារូបិយប័ណ្ណបរទេសរបស់គ្រួសារតាមតំបន់ (រូបភាពទី១) និងតាមកម្រិតនៃប្រាក់ចំណូល (រូបភាពទី២)






**ប្រភព ៖** The NBC-JICA survey 2017

## ៤.២. ចំណូលចិត្តសម្រាប់រូបិយប័ណ្ណតាមទំហំប្រតិបត្តិការ

ការជ្រើសរើសរូបិយប័ណ្ណបរទេសរបស់គ្រួសារកម្ពុជាដូចដែលទ្រឹស្តីបានបង្ហាញគ្រួសារកម្ពុជាជ្រើសរើសរូបិយប័ណ្ណបរទេស ប្រសិនបើទំហំប្រតិបត្តិការកាន់តែធំ។ នៅក្នុងការស្ទង់មតិរបស់ NBC- JICA គ្រួសារនីមួយៗត្រូវបានសួរអំពីចំណូលចិត្តរូបិយប័ណ្ណរបស់ពួកគេក្នុងប្រតិបត្តិការនីមួយៗ។ ជាពិសេស គ្រួសារត្រូវបានស្នើសុំឱ្យជ្រើសរើសរូបិយប័ណ្ណ ដែលពួកគេចង់ទទួលយកក្នុងការលក់ទ្រព្យសម្បត្តិជាក់លាក់ណាមួយរបស់ពួកគេ។ ឧទាហរណ៍ ប្រសិនបើគ្រួសារមួយមានដី គ្រួសារត្រូវបានស្នើសុំឱ្យផ្តល់តម្លៃទីផ្សារប៉ាន់ស្មានដោយខ្លួនឯងនៃទ្រព្យសកម្មរបស់ខ្លួន ហើយជ្រើសរើសរូបិយប័ណ្ណដែលខ្លួនចង់ទទួលបាននៅពេលលក់វា។

ការស្ទង់មតិគ្របដណ្តប់លើទ្រព្យសម្បត្តិប្រាំមួយប្រភេទ៖ (1) អចលនទ្រព្យ (2) គ្រឿងសង្ហារឹមនិងឧបករណ៍ (3) ម៉ូតូ និងរថយន្ត (4) គ្រឿងចក្រ និងឧបករណ៍សម្រាប់អាជីវកម្ម និងការប្រើប្រាស់ផ្ទាល់ខ្លួន (5) បសុសត្វ និង (6) សារពើភ័ណ្ឌសម្រាប់អាជីវកម្មខ្នាតតូច ឬកសិកម្ម។

ក្រាហ្វិកទី៦ បង្ហាញពីអំពីចំណូលចិត្តរូបិយប័ណ្ណ និងទំហំទ្រព្យសកម្ម។ មានទំនោរច្បាស់លាស់ដែលគ្រួសារចូលចិត្តប្រាក់ដុល្លារអាមេរិក នៅពេលដែលចំនួននៃការលក់កាន់តែធំ។ ក្រាហ្វិកទី៧ បង្ហាញពីចំណូលចិត្តរូបិយប័ណ្ណ តាមប្រភេទនៃទ្រព្យសកម្មនៅក្នុងគំរូគ្រួសារទាំងមូល។ ក្នុងការលក់អចលនទ្រព្យ ៨៦.១% នៃអ្នកឆ្លើយសំណួរចូលចិត្តទទួលយករូបិយប័ណ្ណបរទេស។ សម្រាប់ម៉ូតូ និងរថយន្ត ៨៥.១% នៃអ្នកឆ្លើយតប

ចូលចិត្តរូបិយប័ណ្ណបរទេស។ សម្រាប់ការលក់គ្រឿងម៉ាស៊ីន និងឧបករណ៍ ៥២.៧% នៃអ្នកឆ្លើយតបចូលចិត្តប្រាក់ដុល្លារអាមេរិក និងសម្រាប់ការលក់គ្រឿង សង្ហារឹម និងឧបករណ៍ប្រើប្រាស់ ៣៨.១% ចូលចិត្តរូបិយប័ណ្ណបរទេស។ សម្រាប់បសុសត្វ ១៦.០% ចូលចិត្តរូបិយប័ណ្ណបរទេស និងសម្រាប់ការលក់សារពើភ័ណ្ឌសម្រាប់អាជីវកម្ម ឬកសិកម្ម ២០.៥% ចូលចិត្ត រូបិយប័ណ្ណបរទេស។ ជាទូទៅ ទំហំប្រតិបត្តិការនៃអចលនទ្រព្យ ឬម៉ូតូ និងរថយន្តមានទំហំធំជាង ប៉ុន្តែទំហំនៃការចិញ្ចឹមសត្វ ឬសារពើភ័ណ្ឌសម្រាប់អាជីវកម្មខ្នាតតូច និងកសិកម្មមាននិន្នាការតូចជាង។

**ក្រាហ្វិកទី៦** ៖ ចំណង់ចំណូលចិត្តរូបិយប័ណ្ណតាមទំហំនៃប្រតិបត្តិការការលក់




**ក្រាហ្វិកទី៧**៖ ចំណង់ចំណូលចិត្តរូបិយប័ណ្ណសម្រាប់ការលក់ទំនិញ ឬសម្ភារៈផ្សេងៗ




**ប្រភព** ៖ The NBC-JICA survey 2017

## ៤.៣. ការកម្ចីប្រាក់របស់គ្រួសារ

ទិន្នន័យនៃការស្ទង់មតិរបស់ NBC-JICA ក៏បានប្រមូលព័ត៌មានស្តីពីការខ្ចីប្រាក់តាមគ្រួសារផងដែរ។ យើងបង្ហាញទិន្នន័យអំពីរូបិយប័ណ្ណដែលគ្រួសារខ្មែរខ្ចី និងហេតុផលរបស់ពួកគេក្នុងការខ្ចីប្រាក់សម្រាប់រូបិយប័ណ្ណបរទេស។

នៅក្នុងការស្ទង់មតិរបស់ NBC- JICA ឆ្នាំ ២០១៧ គ្រួសារត្រូវបានសួរអំពីព័ត៌មានលម្អិតនៃប្រាក់កម្ចីដែលមិនទាន់មាន។ សំណួរដែលគ្របដណ្តប់លើប្រភេទអ្នកផ្តល់ប្រាក់កម្ចី និកាយរូបិយប័ណ្ណ និងចំនួនប្រាក់កម្ចី។ ក្នុងចំណោម ២,២៧៣ គ្រួសារដែលបានស្ទង់មតិ ៧០០ បានឆ្លើយថាពួកគេមានប្រាក់កម្ចី (តារាងទី៣) ។ ដោយសារគ្រួសារខ្លះមានកម្ចីពីរឬបីកម្ចីសរុបមានចំនួន ៧៨២ ។ ប្រាក់កម្ចីជាដុល្លារអាមេរិកគ្របដណ្តប់យ៉ាងច្បាស់ជាមួយនឹងប្រាក់កម្ចីចំនួន ៥៦០ (៧.៦%) បន្ទាប់មកដោយប្រាក់រៀល (២៤.៦%) និងប្រាក់បាតថៃ (៣.៨%) ។ តាមប្រភេទអ្នកអោយខ្ចី យើងសង្កេតឃើញថា ភាគច្រើននៃប្រាក់កម្ចីពីធនាគារ (៨២.២%) និង MFIs (៦០.៥%) ជាប្រាក់ដុល្លារអាមេរិក។ យើងក៏បានសង្កេតឃើញថា ប្រាក់កម្ចីភាគច្រើនបានមកពីធនាគារឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហើយប្រភពទាំងនេះរួមគ្នាបានរួមចំណែក ៨៨.២% នៃប្រាក់កម្ចីសរុប។

**តារាងទី៣** ៖ ការជ្រើសរើសរូបិយប័ណ្ណផ្សេងៗសម្រាប់ធ្វើការកម្ចីប្រាក់

| *Lender* | *Currency* | | | |
|---|---|---|---|---|
| | *KHR* | *USD* | *THB* | *Total* |
| Commercial bank | 42 | 245 | 10 | 297 |
| Microfinance institution | 108 | 273 | 12 | 393 |
| Family or friends | 20 | 31 | 4 | 55 |
| NGO | 4 | 3 | 0 | 7 |
| Other informal lenders | 16 | 7 | 4 | 27 |
| *Refuse to inform* | 2 | 1 | 0 | 3 |
| Total | 192 | 560 | 30 | 782 |

**ប្រភព** ៖ The NBC-JICA survey 2017

ចំពោះកម្រិតចំណូល និងតាមតំបន់ប្រាក់កម្ចី នៅភ្នំពេញគិតជាដុល្លារទាំងស្រុង ខណៈនៅតំបន់ផ្សេងទៀត (លើកលែងតែខេត្តសៀមរាប) ប្រាក់កម្ចីពី ២០ ទៅ ៣០% ត្រូវបានធ្វើឡើងជាប្រាក់រៀល។ប្រាក់បាតថៃក៏ត្រូវបានប្រើប្រាស់ជារូបិយប័ណ្ណកម្ចីរួមជាមួយនឹងប្រាក់ដុល្លារអាមេរិក និងប្រាក់រៀលខ្មែរនៅក្នុងតំបន់ខាងជើង-

ខាងលិច។ ជាថ្មីម្តងទៀត យើងកត់សំគាល់ថាសមាមាត្រនៃប្រាក់កម្ចីជាប្រាក់រៀលមានការថយចុះជាមួយនឹងការកើនឡើងនៃកម្រិតប្រាក់ចំណូល។

**ក្រាហ្វិកទី៨** ៖ បំណុលរបស់គ្រួសារតាមកម្រិតនៃប្រាក់ចំណូល (រូបភាពទី១) និងតាមតំបន់ (រូបភាពទី២)







**ប្រភព** ៖ The NBC-JICA survey 2017

គ្រួសារត្រូវបានសួរផងដែរ សម្រាប់ហេតុផលកំពូលពីរដែលហេតុអ្វីបានជាពួកគេជ្រើសរើសរូបិយប័ណ្ណទាក់ទងនឹងប្រាក់កម្ចីដែលបានយកចេញក្នុងរយៈពេល ២ ឆ្នាំកន្លងមក។ សំណួរនេះត្រូវបានសួរតែគ្រួសារដែលមានបំណុលនៅពេលនៃការស្ទង់មតិប៉ុណ្ណោះ។ ហេតុផលគួរឱ្យកត់សម្គាល់មួយសម្រាប់ការជ្រើសរើសរូបិយប័ណ្ណបរទេសគឺថាវាងាយស្រួលជាងក្នុងការខ្ចីប្រាក់ជាច្រើនជារូបិយប័ណ្ណបរទេស។

**តារាងទី៤** ៖ មូលហេតុនៃការជ្រើសរើសកម្ចីនៃរូបិយប័ណ្ណផ្សេងៗ

| *I intended to borrow money in a foreign exchange because … (618 respondents)* | *Yes* |
|---|---|
| It is easier to borrow large amounts of money in foreign exchange | 104 |
| The purpose of my loan requires foreign exchange currency amount | 60 |
| I cannot find a loan in KHR for the amount I need | 6 |
| The interest rate of foreign currency is better | 29 |
| The transactions I am involved in require that I pay in foreign currency | 382 |
| Do not want to risk exchange rate loss | 23 |
| Other reasons | 14 |
| *I intended to borrow money in KHR because … (235 respondents)* | *Yes* |
| I would borrow KHR if the amount were less than US$1,000 | 25 |
| Interest rates are better than US dollars | 18 |
| Transactions are in KHR | 123 |
| Do not want to risk exchange rate loss | 35 |
| Other reasons | 34 |

*Source*: The NBC-JICA survey 2017. Authors' calculation.

**ប្រភព** ៖ The NBC-JICA survey 2017

## ៤.៤. ការពិភាក្សា

ការប្រើប្រាស់ប្រាក់ដុល្លាររបស់ប្រទេសកម្ពុជា ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ ១៩៩០ បន្ទាប់ពីជម្លោះ និង អស្ថិរភាពជាច្រើនទសវត្សរ៍ ដែលបានធ្វើឱ្យសេដ្ឋកិច្ចរបស់ប្រទេសចុះខ្សោយយ៉ាងខ្លាំង និងបានបំផ្លាញទំនុកចិត្តសាធារណៈលើរូបិយប័ណ្ណជាតិ គឺប្រាក់រៀលកម្ពុជា។ បន្ទាប់ពីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ ១៩៩០ និងការអន្តរាគមន៍ជាបន្តបន្ទាប់របស់អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅកម្ពុជា ប្រាក់ដុល្លារត្រូវបានចរាចរួមជាមួយប្រាក់រៀលជាផ្នែកមួយដើម្បីស្ថិរភាពសេដ្ឋកិច្ច និងការកសាងប្រទេសជាតិឡើងវិញ។

ក្នុងអំឡុងពេលនេះ ប្រាក់ដុល្លារអាមេរិកបានក្លាយជារូបិយប័ណ្ណដែលពេញចិត្តយ៉ាងឆាប់រហ័សសម្រាប់ទាំងសាធារណជន និងអាជីវកម្ម ដោយសារតែស្ថិរភាព និងការទទួលយកយ៉ាងទូលំទូលាយ។ ប្រាក់ដុល្លារបានហូរចូលកម្ពុជាយ៉ាងច្រើន តាមរយៈលំហូរនៃជំនួយបរទេស ការវិនិយោគ និងការផ្ញើប្រាក់ដែលមានច្រើនលើស

លុបជាប្រាក់ដុល្លារអាមេរិក។ ជាលទ្ធផលប្រាក់រៀលត្រូវបានកាត់បន្ថយទៅជាប្រតិបត្តិការតូចតាចក្នុងស្រុក ខណៈដែលប្រាក់ដុល្លារបានក្លាយជាមធ្យោបាយដោះដូរចម្បងសម្រាប់សកម្មភាពសេដ្ឋកិច្ចភាគច្រើន។

ការប្រើប្រាស់ប្រាក់ដុល្លារបានជួយស្តារប្រព័ន្ធសេដ្ឋកិច្ច ទាក់ទាញវិនិយោគិនពីបរទេស និងបានរួមចំណែកដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនានាក្នុងប្រទេសជាតិ។ យោងតាមប្រសាសន៍របស់លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាលធនាគាជាតិនៃកម្ពុជា "ក្នុងរយៈពេលពីរទសវត្សន៍ចុងក្រោយនេះជាមួយនឹងអត្រាប្តូរប្រាក់មានស្ថិរភាព និងអត្រាអតិផរណាទាប កម្ពុជាបានអនុវត្តន៍យុទ្ធនាការជាបន្តបន្ទាប់ជាច្រើន ដើម្បីលើកកម្ពស់ការយល់ដឹង និងកសាងទំនុកចិត្តរបស់ប្រជាពលរដ្ឋចំពោះការប្រើប្រាស់ប្រាក់រៀលជំនួសរូបិយប័ណ្ណបរទេស"[37] ។

ទន្ទឹមនឹងអត្ថប្រយោជន៍ទាំងនេះ ដុល្លារូបនីយកម្មក៏មានគុណវិបត្តិដែរ វាក៏បានកំណត់សមត្ថភាពរបស់ធនាគារជាតិនៃកម្ពុជាក្នុងការគ្រប់គ្រងគោលនយោបាយរូបិយវត្ថុផងដែរ ដោយសារការប្រើប្រាស់ប្រាក់ដុល្លារយ៉ាងទូលំទូលាយបានកាត់បន្ថយតម្រូវការប្រាក់រៀល និងកាត់បន្ថយអធិបតេយ្យភាពសេដ្ឋកិច្ចរបស់ប្រទេស។ ហេតុនេះហើយ ធនាគារជាតិបានព្យាយាមលើកកម្ពស់ប្រាក់រៀល ចាប់ពីដើមទសវត្សរ៍ឆ្នាំ ២០០០[38]។ ការធ្វើបដិដុល្លារូបនីយកម្មបានជួយលើកតម្កើនរូបិយវត្ថុជាតិ កាត់បន្ថយការប្រើប្រាស់រូបិយប័ណ្ណបរទេស បង្កើនសមត្ថភាពរបស់នាគារជាតិនៃកម្ពុជាក្នុងការគ្រប់គ្រងគោលនយោបាយរូបិយវត្ថុ និងបង្កើនអត្តសញ្ញាណជាតិខ្មែរ។ យោងតាមប្រសាសន៍របស់លោកជំទាវបណ្ឌិត ជា សិរី "ការប្រើប្រាស់ប្រាក់រៀលឱ្យបានទូលំទូលាយនឹងជួយបង្កើនប្រសិទ្ធភាពនៃការអនុវត្ត និងគាំទ្រដល់កំណើនសេដ្ឋកិច្ចជាតិ"[39] ។

ក្នុងឆ្នាំ ២០១៣ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវ មូលបត្រអាចជួញដូរបាន ដើម្បីបង្កើតទីផ្សារប្រាក់ដ៏រឹងមាំជាងមុន និងបង្កើតឧបករណ៍គោលនយោបាយរូបិយវត្ថុដែលពឹងផ្អែកលើប្រាក់រៀល។ នេះត្រូវបានបន្តដោយការដាក់ឱ្យប្រើប្រាស់នូវប្រតិបត្តិការផ្តល់សន្ទនីយភាព ដោយមានការធានាក្នុងឆ្នាំ ២០១៦ ដែលបានជំរុញឱ្យស្ថាប័នហិរញ្ញវត្ថុប្រើប្រាស់ប្រាក់រៀល ដោយផ្តល់ជូនពួកគេនូវប្រាក់រៀលជាថ្នូរនឹងវត្ថុបញ្ចាំប្រាក់ដុល្លារអាមេរិក។

---

[37] Sreekanth Ravindran, "ការធ្វើបដិដុល្លារូបនីយកម្មទទួលបានជោគជ័យយ៉ាងធំធេងនៅតាមបណ្តាខេត្ត", ២៥ មីនា ២០២៤, https://www.khmertimeskh.com/501460137/%E1%9E%80%E1%9E%9A%E1%9E%92%E1%9E%9C%E1%9E%94%E1%9E%8A%E1%9E%8A%E1%9E%9B%E1%9E%9B%E1%9E%9A/ )

[38] Khmertimes, "NBC Governor says Cambodia has seen big increase in local currency usage in past 2 decades.", 11 November 2023, https://www.khmertimeskh.com/501390501/nbc-governor-says-cambodia-has-seen-big-increase-in-local-currency-usage-in-past-2-decades/

[39] សៀកឡេង លាង, វិថីឆ្ពោះទៅបដិដុល្លារូបនីយកម្ម និងការពង្រឹងប្រាក់រៀល, ២១ កញ្ញា ២០២២, https://www.vodkhmer.news/2022/09/21/road-to-dollarization-and-strengthening-of-the-riel/

កិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតក្នុងការលើកកម្ពស់ប្រាក់រៀល រួមមានការអនុញ្ញាតឱ្យចេញមូលបត្របំណុលសាជីវកម្មជាប្រាក់រៀលក្នុងឆ្នាំ ២០១៨ និងការបើកដំណើរការប្រព័ន្ធទូទាត់បាគង[40] ហើយវាជាវេទិកាឌីជីថលក្នុងគោលបំណងសម្រួលដល់ប្រតិបត្តិការជាប្រាក់រៀលផងដែរ។ ធនាគារជាតិនៃកម្ពុជាក៏បានចាត់វិធានការសំខាន់ៗក្នុងឆ្នាំ ២០២០ គឺលុបបំបាត់ក្រដាសប្រាក់ដុល្លារអាមេរិកនិកាយខ្នាតតូច ដោយហេតុនេះជំរុញឱ្យការប្រើប្រាស់ប្រាក់រៀលសម្រាប់ប្រតិបត្តិការប្រចាំថ្ងៃ។

[40] ធនាគារជាតិនៃកម្ពុជា, "របាយការណ៍ប្រចាំឆ្នាំ២០២៣", បានចូលទាញនៅថ្ងៃទី៣ សីហា ២០២៤, https://www.nbc.gov.kh/download_files/publication/annual_rep_kh/Annual_Report_2023_KHM.pdf

# សេចក្ដីសន្និដ្ឋាន និងអនុសាសន៍

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## សេចក្តីសន្និដ្ឋាន

ឆ្លងតាមការបកស្រាយប្រធានបទខាងលើនេះ ដុល្លារូបនីយកម្ម គឺសំដៅដល់បាតុភូតដែលប្រជាពលរដ្ឋនៃប្រទេសមួយបានសម្រេចចិត្តជ្រើសរើសប្រើប្រាស់រូបិយប័ណ្ណបរទេស។ ការលេចចេញរូបិយប័ណ្ណបរទេសនៅកម្ពុជា អាចបណ្តាលមកពីការបាត់បង់ទំនុកចិត្តពីសាធារណជនចំពោះរូបិយប័ណ្ណជាតិប្រាក់រៀល។ ការបាត់បង់ទំនុកចិត្តនេះកើតចេញពីភាពតក់ស្លុតជាបន្តបន្ទាប់ រួមទាំងការបំផ្លិចបំផ្លាញដែលបង្កឡើងដោយខ្មែរក្រហម និងការគ្រប់គ្រងសេដ្ឋកិច្ចមិនត្រឹមត្រូវ។ ទោះបីជារដ្ឋាភិបាលកម្ពុជា មិនដែលបានអនុម័តជាផ្លូវការនូវរូបិយប័ណ្ណបរទេសក៏ដោយក៏កម្ពុជាបានក្លាយជាប្រទេសដែលមានសេដ្ឋកិច្ចដុល្លារច្រើនជាងគេនៅលើពិភពលោក។ ប្រាក់ដុល្លារអាមេរិកត្រូវបានប្រើប្រាស់មិនត្រឹមតែសម្រាប់ប្រតិបត្តិការពាណិជ្ជកម្មប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់ប្រតិបត្តិការប្រចាំថ្ងៃផងដែរ។

យ៉ាងណាមិញ បដិដុល្លារូបនីយកម្ម គឺជាដំណើរការនៃការកាត់បន្ថយការពឹងផ្អែកលើរូបិយប័ណ្ណបរទេសរបស់ប្រទេសមួយ។ ចំពោះប្រទេសកម្ពុជា ដុល្លារូបនីយកម្មបានផ្តល់ទាំងឱកាស និងបញ្ហាប្រឈមសម្រាប់ខ្លួន។ អត្ថប្រយោជន៍មានដូចជាស្ថិរភាពថ្លៃ និងការសម្របសម្រួលក្នុងការទូទាត់ទំនិញនានា ចំពោះគុណវិបត្តិវិញ យើងឃើញថា វាបានរារាំងការគ្រប់គ្រងនៃគោលនយោបាយរូបិយវត្ថុ។

ដូចនេះ ការចាយលុយរៀល ដែលជារូបិយប័ណ្ណជាតិ និងការគ្រប់គ្រងនយោបាយរូបិយវត្ថុយ៉ាងពេញលេញដោយខ្លួនឯង វាមិនត្រឹមតែផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ចជាតិប៉ុណ្ណោះទេ តែវាក៏ជាមោទនភាពរបស់ជាតិខ្មែរទាំងមូលផងដែរ។ ក៏ប៉ុន្តែ ដើម្បីឱ្យលុយរៀលត្រូវបានគេប្រើប្រាស់ច្រើន និងជាមោទនភាពរបស់ជាតិខ្មែរ បានរដ្ឋាភិបាលកម្ពុជាចាំបាច់ត្រូវតែដាក់ចេញនូវនយោបាយ ដើម្បីស្តារទំនុកចិត្តលើលុយរៀលឡើងវិញ។

# អនុសាសន៍

ដូច្នេះកម្ពុជាត្រូវបង្កើតយុទ្ធសាស្ត្ររយៈពេលវែង និងផែនការជំរុញការប្រើប្រាស់ប្រាក់រៀលជាបន្តបន្ទាប់តាមរយៈការបង្កើនទំនុកចិត្តសាធារណជនលើប្រាក់រៀល សេដ្ឋកិច្ចក្នុងស្រុក និងវិស័យហិរញ្ញវត្ថុ តាមរយៈការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច។ ជាមួយគ្នានេះកម្ពុជាត្រូវជំរុញការប្រើប្រាស់ប្រាក់រៀល តាមរយៈវិធានការរដ្ឋបាលផ្សេងៗ ដោយផ្អែកលើគោលការណ៍ទីផ្សារ ដែលស្របតាមស្ថិរភាពនយោបាយម៉ាក្រូសេដ្ឋកិច្ច។

អត្ថប្រយោជន៍ចម្បងមួយនៃការធ្វើបដិដុល្លារូបនីយកម្មគឺ សក្តានុពលក្នុងការទទួលបានឯករាជ្យភាពគោលនយោបាយរូបិយវត្ថុឡើងវិញ ដូចជាអនុញ្ញាតឱ្យធនាគារកណ្តាលរបស់កម្ពុជាអនុវត្តការកែសម្រួលអត្រាការប្រាក់ និងឧបករណ៍រូបិយវត្ថុផ្សេងទៀត ដើម្បីគ្រប់គ្រងស្ថានភាពសេដ្ឋកិច្ចក្នុងស្រុកឱ្យកាន់តែមានប្រសិទ្ធភាព។ ដើម្បីជំរុញការធ្វើបដិដុល្លារូបនីយកម្ម និងការលើកកម្ពស់ប្រាក់រៀលរួមមាន៖

១. លើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលក្នុងវិស័យសំខាន់ៗ

២. រក្សាប្រព័ន្ធរូបិយប័ណ្ណជាមួយនឹងការការគ្រប់គ្រងលំហូរប្រាក់ដុល្លារអាមេរិក

៣. ពង្រឹងស្ថិរភាព និងបង្កើនទំនុកចិត្តទៅលើប្រាក់រៀល

៤. អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងសុខុមាលភាពសង្គម

៥. ជំរុញការវិនិយោគពីបរទេស និងការធ្វើពាណិជ្ជកម្មពីបណ្តាប្រទេសផ្សេងៗ។

# ឯកសារយោង

# ឯកសារយោង

## ឯកសារជាភាសាខ្មែរ


1. Wikipedia, “រូបិយវត្ថុ”, បានកែសម្រួលនៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២៣, រូបិយវត្ថុ - វិគីភីឌា (wikipedia.org)
2. ដកស្រង់ចេញពីវចនានុក្រមខ្មែររបស់ **សម្តេចសង្ឃ ជួន ណាត**, បានចូលទាញនៅថ្ងៃទី១៥ មិថុនា ២០២៤
3. គេហទំព័រ Facebook (ស្វែងយល់ពាក្យបច្ចេកទេស), “មុខងាររូបិយវត្ថុ”, ០៨ កក្កដា ២០១៩, https://www.facebook.com/share/1YhrZAJLL9P6mGcw/?mibextid=WC7FNe
4. ដកស្រង់ចេញពី លោកសាស្ត្រាចារ្យ ងួន ហេង, “សៀវភៅរូបិយវត្ថុ និងធនាគារ”, ឆ្នាំ២០១៥, ទំព័រ៨&៩, បានចូលទាញនៅថ្ងៃទី២០ ឧសភា ២០២៤
5. Sem Kimchhay, “ដុល្លារូបនីយកម្ម”, ០៥ កុម្ភៈ ២០១៧, ដុល្លារូបនីយកម្ម - វិគីភីឌា (wikipedia.org)
6. Cambonomic Times, “ដុល្លារូបនីយកម្ម”,២៩ ឧសភា ២០២០, https://www.facebook.com/share/zxGNCfvppTiFKHpF/?mibextid=WC7FNe
7. Khemsaritheducation, “គុណសម្បត្តិ និងគុណវិបត្តិរបស់ដុល្លារូបនីយកម្ម”, ២១ ឧសភា 2018, https://khemsaritheducation.wordpress.com/
8. ធន់ សេងហុង, “តើគោលនយោបាយរូបិយវត្ថុជាអ្វី?”, ១២ តុលា ២០២៣, https://thmeythmey.com/?page=detail&id=130758
9. ធនាគារជាតិនៃកម្ពុជា, “ទិដ្ឋភាពទូទៅនៃគោលនយោបាយរូបិយវត្ថុ”, បានចូលទាញនៅថ្ងៃទី ២០ កក្កដា ២០២៤, https://www.nbc.gov.kh/monetary_policy/overview.php
10. ធនាគារជាតិនៃកម្ពុជា, “សារៈប្រយោជន៍នៃការប្រើប្រាស់ប្រាក់រៀល”, ៤ ឧសភា ២០២២, https://www.nbc.gov.kh/
11. Sreekanth Ravindran, “ការធ្វើបដិដុល្លារូបនីយកម្មទទួលបានជោគជ័យយ៉ាងធំធេងនៅតាមបណ្តាខេត្ត”, ២៥ មីនា ២០២៤, https://www.khmertimeskh.com/501460137/%E1%9E%80%E1%9E%9A%E1%9E%92%E1%9E%9C%E1%9E%94%E1%9E%8A%E1%9E%8A%E1%9E%9B%E1%9E%9B%E1%9E%9A/
12. សៀកឡេង លាង, “វិថីឆ្ពោះទៅបដិដុល្លារូបនីយកម្ម និងការពង្រឹងប្រាក់រៀល”, ២១ កញ្ញា ២០២២, https://www.vodkhmer.news/2022/09/21/road-to-dollarization-and-strengthening-of-the-riel/

13. ធនាគារជាតិនៃកម្ពុជា, "របាយការណ៍ប្រចាំឆ្នាំ២០២៣", បានចូលទាញនៅថ្ងៃទី៣ សីហា ២០២៤, https://www.nbc.gov.kh/download_files/publication/annual_rep_kh/Annual_Report_2023_KHM.pdf

## ឯកសារជាភាសាបរទេស


1. Sovannroeun Samreth et al, “Development and Structure of Dollarization in Cambodia.”, accessed 02 July 2024, https://www.jica.go.jp/english/jica_ri/publication/booksandreports/1517598_24204.html
2. Luke Hunt, “Cambodia Aims to Reduce Dependency on US Dollar.”, 07 March 2021, Cambodia Aims to Reduce Dependency on US Dollar (voanews.com)
3. Ross, R.1990. “Cambodia: A Country Study. Washington, DC: Library of Congress, Federal Research Division.”, accessed 02 July 2024.
4. Samreth Sovannroeun and Okuda Hidenobu, “Economic Growth and Dollarization in Cambodia.”, 01 January 2019, アジア研究 (jst.go.jp)
5. Kuoch, S., and S. Samreth, “Labour Force and Labour Market in Cambodia: Facts, Challenges and Policy Actions.” In Human resource Landscape in Mainland ASEAN, edited by S. Bunnag, and P. Srisangnam, 1-23. Bangkok: Chulalongkorn University Press., 2020.
6. Zamaróczy, M., and S. Sa., “Economic Policy in a Highly Dollarized Economy: The Case of Cambodia.”, Washington, DC: International Monetary Fund, 2022.
7. Lay, S., M. Kakinaka, and K. Kotani, “Exchange Rate Movement in Dollarized Economy.” ASEAN Economic Bulletin 29(1): 65-78, 2012.
8. International Monetary Fund, “Cambodia: Staff Report for the 2010 Article IV Consultation.”, Washington, DC: International Monetary Fund, 2011.
9. Kang, K., “Is Dollarization Good for Cambodia?” Global Economic Review 34(2): 201-211, 2005.
10. Menon, J., “Cambodia’s Persistent Dollarization.”, ASEAN Economic Bulletin, 25: 228-237, 2008a.
11. Menon, J. “Dealing with Multiple Currencies.”, Journal of the Asia Pacific Economy 13: 131-146, 2008b.
12. Unteroberdoerster, O., “Banking Reform in the Lower Mekong Countries.”, Washington, DC: International Monetary Fund, 2004.

13. Khou, V., “Cambodia’s Monetary Plicy: Dollarization, Managing National Currency Supply and Exchange Rate Stability.”, Paper presented at the Conference of the Japan Association of Asian Studies, Keio University, 31 May 2014.
14. World Bank, “World Development Indicators.”, Washington, DC: World Bank, 2021a, https://data.worldbank.org/products/wdi
15. International Labour Organization, “The Footwear Sector: New Opportunities for Cambodia？”, Cambodia Garment and Footwear Sector Bulletin 9, 2019.
16. Hang, C., “The Cambodian Economy: Charting the Course of a Brighter Future.”, Singapore: Institute of Southeast Asian Studies, 2012.
17. Daiju Aiba and Sovanney Chey, “Its Policy Implications for LDCs’ Financial Development.", accessed 01 August 2024, https://www.jica.go.jp/english/jica_ri/news/topics/2023/1520896_24294.html
18. Vouthy Khou et al, "Dollarization in households.", accessed 03 August 2024, https://www.jica.go.jp/english/jica_ri/news/topics/2023/1520896_24294.html
19. Khmertimes, "NBC Governor says Cambodia has seen big increase in local currency usage in past 2 decades.", 11 November 2023, https://www.khmertimeskh.com/501390501/nbc-governor-says-cambodia-has-seen-big-increase-in-local-currency-usage-in-past-2-decades/

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

## <u>ឧបសម្ព័ន្ធទី ១ ៖</u>

---

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.៩៣៣..០២១..០០៦.ប្រកាសព័ត៌មាន

*ថ្ងៃ អង្គារ ៤កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥*
*រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២១*

**សេចក្តីប្រកាសព័ត៌មាន ស្តីពី**
**ការលើកកម្ពស់គុណភាពថ្លៃប្រាក់រៀល**

ក្រោមកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជា និងភាគីពាក់ព័ន្ធទាំងអស់ ប្រាក់រៀលត្រូវបានបង្កើនតួនាទីជាលំដាប់នៅក្នុងសេដ្ឋកិច្ចនិងសង្គម ប្រកបដោយនិរន្តរភាពនិង ជំនឿទុកចិត្ត ដែលបម្រើផលប្រយោជន៍ដល់ប្រជាជនកម្ពុជាគ្រប់លំដាប់ថ្នាក់ និងសេដ្ឋកិច្ចជាតិ ទាំងមូល។

ក្នុងស្ថានភាពនៃការរីករាលដាលជំងឺកូវីដ-១៩ ធនាគារជាតិនៃកម្ពុជាសូមលើកទឹកចិត្តឱ្យ សាធារណជនទាំងអស់ប្រើប្រាស់នូវការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក និងប្រើប្រាស់ក្រដាស ប្រាក់រៀលប្រកបដោយអនាម័យខ្ពស់។ កន្លងមក ដើម្បីបង្កើនការយល់ដឹងនិងលើកកម្ពស់គុណភាពថ្លៃ របស់ប្រាក់រៀល ធនាគារជាតិនៃកម្ពុជា ក៏បានផ្សព្វផ្សាយអំពីរបៀបនៃការទុកដាក់និងប្រើប្រាស់ ក្រដាសប្រាក់រៀលឱ្យបានត្រឹមត្រូវនិងប្រកបដោយអនាម័យតាមរយៈ វីដេអូខ្លី និងឯកសារអប់រំ ផ្សេងៗផងដែរ។ ក្រដាសប្រាក់រៀលចាស់ ទក់ រហែក អាចយកមកប្តូរថ្មីដោយមិនគិតកម្រៃសេវា នៅគ្រប់បញ្ជរបេឡារបស់សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត (លើកលែងតែស្នាក់ការកណ្តាល) នៅរៀងរាល់ម៉ោងធ្វើការ។ ក្នុងករណីដែលក្រដាសប្រាក់រៀលមានការខូចខាតឬបាត់បង់ទ្រង់ទ្រាយ ដូចមានចែងក្នុងមាត្រា ៥១ មាត្រា ៥២ និងមាត្រា ៥៣ នៃច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃ ធនាគារជាតិនៃកម្ពុជា (១៩៩៦) ធនាគារជាតិនៃកម្ពុជា សូមរក្សាសិទ្ធិដកហូតដោយគ្មានសំណង។

មាត្រា ៥១ ចែងថា "**ធនាគារកណ្តាលអាចបដិសេធមិនប្តូរក្រដាសប្រាក់និងកាស បើសិនជា រូបភាពវាលែងមានភាពច្បាស់លាស់ បាត់បង់រូបភាពដើមឬផ្ទុះធ្លាយឬដែលបាត់បង់ទំហំ ៣០% (សាមសិបភាគរយ) ឬលើសពីនេះ។ រូបិយវត្ថុទាំងនេះត្រូវដកចេញពីចរាចរហើយបំផ្លាញចោល ដោយគ្មានសំណងចំពោះម្ចាស់ទេ លើកលែងតែករណីពិសេសដែលធនាគារកណ្តាលអាចយល់ព្រម សងមួយចំណែកឬទាំងអស់**"។

មាត្រា ៥២ ចែងថា "**ក្រដាសប្រាក់ក្លែងក្លាយដែលយកមកបង់ឬប្តូរត្រូវរឹបអូសដោយគ្មានសំណង ហើយត្រូវជូនព័ត៌មានទៅអាជ្ញាធរមានសមត្ថកិច្ច**"។



ប្រអប់សំបុត្រលេខ ២៥, អគារលេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៩២៦ ១១៧

**មាត្រា ៥៣ ចែងថា "ម្ចាស់ប្រាក់មិនអាចទាមទារពីធនាគារកណ្តាលឱ្យសង ចំពោះក្រដាសប្រាក់ឬកាសណាដែលខ្លួនធ្វើឱ្យបាត់បង់ឬធ្វើឱ្យអន្តរាយឡើយ។ ធនាគារកណ្តាលអាចដកហូតយកដោយគ្មានថ្នូរនូវក្រដាសប្រាក់ដែលមានការខូចខាតរូបភាពក្រៅ ជាពិសេសចំពោះក្រដាសប្រាក់ណាដែលមានសរសេរ លាបពណ៌ បោះពុម្ព បោះត្រាឬបិទវត្ថុស្អិតពីលើឬឆ្លុះធ្លាយឬបាត់រូបភាពដោយប្រការណាក៏ដោយ"។**

ប្រាក់រៀលតំណាងឱ្យអត្តសញ្ញាណជាតិ អធិបតេយ្យភាពជាតិ ឯករាជ្យភាពសេដ្ឋកិច្ច និងពង្រឹងសាមគ្គីភាពសង្គម។ ធនាគារជាតិនៃកម្ពុជាសូមថ្លែងអំណរគុណ និងសង្ឃឹមថាគ្រប់ភាគីពាក់ព័ន្ធទាំងអស់ជាពិសេសប្រជាជនកម្ពុជាយើង នឹងបន្តស្មារតីសហការលើកកម្ពស់ប្រាក់រៀលជាតិ និងរួមចំណែកយ៉ាងសកម្មក្នុងការប្រឆាំងនឹងទង្វើទាំងឡាយណា ដែលប៉ះពាល់ដល់គុណតម្លៃប្រាក់រៀលរបស់យើង។

**ទំនាក់ទំនង ៖**
ផ្នែកទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៩០ ១៩៦
អ៊ីម៉ែល ៖ nbccommunication@nbc.org.kh

<u>**ឧបសម្ព័ន្ធទី ២ ៖**</u>

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.......................................................

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សុន្ទរកថា**

**លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាលធនាគារជាតិនៃកម្ពុជា**

**ក្នុងសិក្ខាសាលាផ្សព្វផ្សាយសៀវភៅ ស្តីពី**

**"ដុល្លារូបនីយកម្មនៅកម្ពុជា៖ ទំនាក់ទំនងផ្នែកគោលនយោបាយក្នុងការអភិវឌ្ឍ**

**ហិរញ្ញវត្ថុសម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច"**

នៅសណ្ឋាគារ Raffles Le Royal

ថ្ងៃសុក្រ ១២រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ត្រូវនឹងថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៣

**សូមគោរព៖**

- **ឯកឧត្តម ជា ចាន់តូ អគ្គទេសាភិបាលកិត្តិយសធនាគារជាតិនៃកម្ពុជា ជាទីគោរព**
- **លោក TANINAI Ichitomo អនុប្រធានបេសកកម្មនៃស្ថានទូតជប៉ុនប្រចាំកម្ពុជា**
- **លោក Kazumasa Sanui ប្រធានតំណាង JICA ប្រចាំកម្ពុជា**
- **ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

តាងនាមធនាគារជាតិនៃកម្ពុជា ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអនេកដែលបានចូលរួមក្នុងពិធីផ្សព្វផ្សាយសៀវភៅស្តីពី "ដុល្លារូបនីយកម្មនៅកម្ពុជា៖ ទំនាក់ទំនងផ្នែកគោលនយោបាយក្នុងការអភិវឌ្ឍហិរញ្ញវត្ថុសម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច" ដែលទើបតែត្រូវបានបោះផ្សាយដោយរោងពុម្ពអន្តរជាតិ Rouledge នៃចក្រភពអង់គ្លេស កាលពីខែកញ្ញាកន្លងទៅនេះ។ ខ្ញុំសូមស្វាគមន៍និងថ្លែងអំណរគុណចំពោះ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញាទាំងអស់ ដែលឆ្លៀតឱកាសដ៏មានតម្លៃចូលរួមក្នុងពិធីនាពេលនេះ ទាំងការចូលរួមដោយផ្ទាល់ និងតាមប្រព័ន្ធអនឡាញ លើបណ្តាញសង្គមរបស់ធនាគារជាតិនៃកម្ពុជា។



ប្រអប់សំបុត្រលេខ ២៥, ផ្ទះលេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

សៀវភៅនេះ គឺជាលទ្ធផលនៃកិច្ចសហការស្រាវជ្រាវរួមគ្នារវាងធនាគារជាតិនៃកម្ពុជា និងវិទ្យាស្ថានស្រាវជ្រាវនៃទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ចាប់តាំងពីឆ្នាំ២០១៣ មកម្ល៉េះ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ JICA ដែលបានរួមចំណែកក្នុងការស្រាវជ្រាវដ៏មានសារៈសំខាន់នេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណជាពិសេសចំពោះលោកសាស្ត្រាចារ្យ Hidenobu Okuda ដែលបានសហការរៀបចំ ដឹកនាំ និងកែសម្រួលខ្លឹមសារនៃអត្ថបទស្រាវជ្រាវ និងអ្នកនិពន្ធគ្រប់រូបដែលបានរួមចំណែកស្រាវជ្រាវលើផ្នែកនីមួយៗ ដែលបានធ្វើឱ្យសៀវភៅនេះ ក្លាយជាមូលដ្ឋានមួយសម្រាប់ការស្រាវជ្រាវថ្មីៗបន្ថែមទៀត កាន់តែស៊ីជម្រៅ និងជាធាតុចូលយ៉ាងសំខាន់ក្នុងការរៀបចំតាក់តែងគោលនយោបាយនានាដើម្បីលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ដូចដែលលោក Kazumasa Sanui បានលើកឡើង។

- **ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា ទាំងអស់ជាទីមេត្រី!**

ដុល្លារូបនីយកម្មបានកើតឡើងក្នុងស្ថានភាពដែលជំនឿទុកចិត្តលើប្រាក់រៀលមានភាពទន់ខ្សោយ ក្រោយពីសង្គ្រាមស៊ីវិលជិត៣ទសវត្សរ៍ និងការហូរចូលយ៉ាងច្រើនសន្ធឹកសន្ធាប់នៃប្រាក់ដុល្លារអាមេរិក ក្នុងពេលរៀបចំការបោះឆ្នោតសកលលើកដំបូងនៅកម្ពុជា ដោយអាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិប្រចាំកម្ពុជា ដែលហៅកាត់ថា UNTAC។ ជាការពិត ដុល្លារូបនីយកម្មបានរួមចំណែកជួយស្តារសេដ្ឋកិច្ច និងអមដំណើរនៃការសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ ជាមួយនឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ក្នុងរយៈពេលជាងពីរទសវត្សរ៍ចុងក្រោយនេះ។ ទោះយ៉ាងណា ដុល្លារូបនីយកម្មខ្ពស់ បានដាក់កំហិតលើការអនុវត្តគោលនយោបាយរូបិយវត្ថុ។ នៅពេលដែលទំហំសេដ្ឋកិច្ចកម្ពុជាកើនឡើងកាន់តែធំ ការខ្វះលទ្ធភាពប្រើប្រាស់គោលនយោបាយរូបិយវត្ថុដោយពេញលេញ ក៏ធ្វើឱ្យសេដ្ឋកិច្ចកាន់តែងាយរងគ្រោះផងដែរ ហើយដែលបណ្តាលឱ្យពឹងផ្អែកតែទៅលើគោលនយោបាយសារពើពន្ធ។ បច្ចុប្បន្ន ស្ទើរតែគ្រប់ប្រទេសទាំងអស់ លំហគោលនយោបាយសារពើពន្ធបានរួមតូចទៅៗ ដោយសារតែវិបត្តិផ្ទួនៗ ហើយប្រទេសនានាលើពិភពលោក បានពឹងផ្អែកកាន់តែច្រើនលើគោលនយោបាយរូបិយវត្ថុ ដើម្បីស្តារកំណើនសេដ្ឋកិច្ច។ ជាក់ស្តែង នៅក្នុងពេលវិបត្តិហិរញ្ញវត្ថុសកលឆ្នាំ ២០០៧-២០០៨ ធនាគារកណ្តាលជាច្រើនបានកាត់បន្ថយអត្រា

ការប្រាក់គោលរហូតដល់ស្ទើរស្មើសូន្យ ដើម្បីជំរុញការវិនិយោគនិងការប្រើប្រាស់ ហើយក្នុងអំឡុងវិបត្តិកូវីដ-១៩ ធនាគារកណ្តាលថែមទាំងបញ្ចេញសាច់ប្រាក់ដើម្បីជួយសេដ្ឋកិច្ចទៀតផង ដែលការអនុវត្តនេះត្រូវបានគេហៅថាគោលនយោបាយរូបិយវត្ថុវិសាមញ្ញ (Unconventional Monetary Policies)។ ចំណែកឯ នៅក្រោយវិបត្តិកូវីដ-១៩ ធនាគារកណ្តាលភាគច្រើនបានបង្កើនអត្រាការប្រាក់គោលមកវិញ ដើម្បីប្រឆាំងនឹងការកើនឡើងនៃអតិផរណា។ លទ្ធភាពក្នុងការបង្កើនឬបន្ថយអត្រាការប្រាក់គោល ឬចាក់បញ្ចូលសន្ទនីយភាពទៅក្នុងសេដ្ឋកិច្ចបានប្រកបដោយប្រសិទ្ធភាព គឺអាស្រ័យលើការប្រើប្រាស់ពេញលេញ និងទូលំទូលាយនៃរូបិយវត្ថុជាតិ។

ក្នុងរយៈពេលជាងពីរទសវត្សរ៍ចុងក្រោយនេះ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ជាពិសេសស្ថិរភាពនយោបាយ បានផ្តល់ភាពអំណោយផលដល់ការពង្រឹងការប្រើប្រាស់ប្រាក់រៀលជាលំដាប់ ខណៈដែលសមាមាត្រនៃការប្រើប្រាស់ដុល្លារអាមេរិកនៅតែមានកម្រិតខ្ពស់។ បញ្ហានេះស្របទៅនឹងការរកឃើញនានារបស់អ្នកស្រាវជ្រាវ ដែលថាពេលដែលដុល្លារូបនីយកម្មកើនដល់ចំណុចខ្ពស់មួយហើយ នឹងមិនងាយថយចុះវិញបានទេ (Hysterisis of Dollarization) គឺតម្រូវឱ្យមានការអនុវត្តគោលនយោបាយលើកទឹកចិត្តផងនិងគាំទ្រផងដើម្បីកាត់បន្ថយកម្រិតដុល្លារូបនីយកម្ម។

ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលនិងធនាគារជាតិនៃកម្ពុជា បានពង្រឹងជំនឿទុកចិត្តរបស់សាធារណជនមកលើប្រាក់រៀលជាប្រចាំ និងបានអនុវត្តវិធានការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលផ្អែកលើយន្តការទីផ្សារ ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ២០០០មក។ កត្តាទាំងនេះបានបង្កើនបរិមាណប្រាក់រៀលក្នុងចរាចរណ៍ពី ០,៨៥ទ្រីលានរៀលកាលពី២០ឆ្នាំមុនដល់១៤,៥ទ្រីលានរៀលនាពេលបច្ចុប្បន្ន ពោលគឺកើនឡើងប្រមាណ ១៦ ដង ស្របតាមការរីកចម្រើននៃសេដ្ឋកិច្ច។ កំណើននេះជាជំហាននិងជាក្តីសង្ឃឹមដ៏សំខាន់ ដើម្បីឈានទៅបង្កើនការប្រើប្រាស់ប្រាក់រៀលបន្ថែមទៀត។

ខ្ញុំសូមគូសបញ្ជាក់ថា ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលមិនមែនជាការងារ ឬការទទួលខុសត្រូវផ្តាច់មុខ របស់ក្រសួង-ស្ថាប័ន ឬវិស័យណាមួយឡើយ តែគឺជាការងាររួមរបស់គ្រប់ក្រសួង-ស្ថាប័ន វិស័យឯកជន និងប្រជាជនទូទៅទាំងអស់គ្នា

ដែលទាមទារ ការសហការនិងគាំទ្របន្ថែមទៀត ឱ្យកាន់តែសកម្មនិងមានសង្គតិភាព។ ក្នុងន័យនេះ ខ្ញុំក៏សូមវាយតម្លៃខ្ពស់ចំពោះ ការចូលរួមចំណែកពីគ្រប់ភាគីទាំងអស់ លើការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល។ ជាក់ស្តែង មានក្រុមហ៊ុន-សហគ្រាសកាន់តែច្រើន បានបើកប្រាក់បៀវត្សរ៍ដល់បុគ្គលិក-និយោជិតជាប្រាក់រៀល នៅតាមទីផ្សារទំនើបនានាក៏បាន បិទស្លាកថ្លៃជារៀល គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុភាគច្រើនក៏បានខិតខំបង្កើនឥណទាន និងប្រតិបត្តិការរបស់ខ្លួនជាប្រាក់រៀល។ ទាំងនេះគឺជាវឌ្ឍនភាពមួយដ៏សំខាន់ សម្រាប់ការ អនុវត្តវិធានការបន្តបន្ទាប់ទៀតដោយពិលាស។

- **ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា ទាំងអស់ជាទីមេត្រី!**

ខ្ញុំសូមចូលរួមអបអរសាទរចំពោះការបោះផ្សាយសៀវភៅស្តីពី "ដុល្លារូបនីយកម្មនៅកម្ពុជា" របស់យើងនាពេលនេះ។ ខ្ញុំសង្ឃឹមថាលទ្ធផលនៃការស្រាវជ្រាវនេះនឹងផ្តល់បទពិសោធន៍ដ៏មានតម្លៃផងដែរដល់ប្រទេសកំពុងអភិវឌ្ឍន៍នានា ក្នុងការគ្រប់គ្រងបញ្ហាដុល្លារូបនីយកម្ម និងការប្រើប្រាស់គោលនយោបាយ ក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនិងសេដ្ឋកិច្ច ឱ្យបានកាន់តែប្រសើរ។ ខ្ញុំក៏មានសេចក្តីសោមនស្សរីករាយផងដែរ ដែលការសម្ពោធសៀវភៅនេះធ្វើឡើងក្នុងឱកាសនៃខួប ៧០ឆ្នាំនៃចំណងការទូតមិត្តភាពកម្ពុជា-ជប៉ុន ដែលបង្ហាញកាន់តែច្បាស់ពីមិត្តភាពដ៏រឹងមាំនិងយូរអង្វែងរបស់កម្ពុជា-ជប៉ុន ព្រមទាំងការចូលរួមចំណែករបស់ប្រទេសជប៉ុន ក្នុងការគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកម្ពុជា។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះទីភ្នាក់ងារ JICA អ្នកស្រាវជ្រាវ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដែលចូលរួមផ្តល់កិច្ចសហការ ក៏ដូចជាការគាំទ្រ ដើម្បីឱ្យការស្រាវជ្រាវ និងរៀបចំតាក់តែងសៀវភៅរបស់យើងអាចបញ្ចប់ទៅបានប្រកបដោយជោគជ័យ និងមានគុណតម្លៃខ្ពស់ក្នុងមជ្ឈដ្ឋានស្រាវជ្រាវ។

**សូមអរគុណ**